ឆ្នាំនៃធម៌មេត្តាករុណា
YEAR OF CHARITY
ជីវិត
Life
ចេញផ្សាយលេខៈ ៣៤
ភូមិភាគភ្នំពេញថ្ងៃទី០១-៣០ ខែមិថុនា ឆ្នាំ២០១៥
ព្រឹត្តិបត្រព័ត៌មានពីព្រះសហគមន៍កាតូលិក
CARITAS CHRISTI URGET NOS
2014-2016

# អបអរសាទរពិធីទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ របស់លោកឧបដ្ឋាក សិលា សុខ ណា



## សេចក្តីជូនដំណឹង

" ឈាមរបស់មរណសាក្សីគឺគ្រាប់ពូជរបស់ព្រះសហគមន៍"(Apologeticus, Chapter 50:Tertullian)។

បងប្អូនជាទីស្រឡាញ់ ព្រះសហគមន៍កាតូលិកកម្ពុជាលូតលាស់ដោយសារឈាមមរណសាក្សី។ ខ្ញុំ, លោកបូជាចារ្យ រឿង ឆ័ត្រសិរី អ្នករៀបចំសុំណុំរឿង (Postulator) បានប្រមូលព័ត៌មានមួយចំនួនហើយ ប៉ុន្តែ សូមបងប្អូនជួយផ្តល់ព័ត៌មានបន្ថែមអំពីអ្នកបម្រើរបស់ព្រះជាម្ចាស់ថែមទៀត ដូចជា៖ រូបថត អត្ថបទឬសៀវភៅដែលគាត់សរសេរ វត្ថុអនុស្សាវរីយរបស់គាត់ខ្លះ ។ល។ សូមផ្តល់ឈ្មោះអ្នកដែលអាចផ្តល់សក្ខីភាពបាន ជូនមកឲ្យខ្ញុំ តាមរយៈអ៊ីម៉ែល martyrscambodia@gmail.com ឬទូរស័ព្ទ 077 800 211 / 096 34 22 144 សូមអរគុណ!



# ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ

## សារលិខិតរបស់លោកអភិបាលអូលីវីយេ
## នៅថ្ងៃសៅរ៍ ទី២៧ ខែមិថុនា ឆ្នាំ២០១៥
## ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានទទួលស្វាគមន៍
## លោកសិលា សុខ ណា ជាបូជាចារ្យថ្មី

**បងប្អូនជាទីស្រឡាញ់!**

យើងអរគុណព្រះគុណព្រះជាម្ចាស់សម្រាប់អំណោយទានរបស់លោកបូជាចារ្យ សុខ ណា។ យើងសូមអង្វរព្រះអម្ចាស់នៃយើង សូមទ្រង់ប្រទានពរដល់លោកក្នុងបេសកកម្មបម្រើព្រះសហគមន៍និងដើម្បីស្រឡាញ់បងប្អូននៅមណ្ឌលសកម្មភាពភ្នំពេញខាងត្បូង។ ជាការពិត គឺស្រឡាញ់អស់អ្នកដែលស្វែងរកពន្លឺនៃសេចក្តីសុខសាន្ត និងធម៌មេត្តាករុណាក្នុងជីវិតប្រចាំថ្ងៃរបស់គេ។

នៅពេលនេះ ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ មានបូជាចារ្យជាតិកម្ពុជាចំនួន ៣នាក់ រួមទាំងលោកឪពុក អ៊ុន សុន លោកឪពុក សួន ហង្សលី ដែលបានទទួលអគ្គសញ្ញាតែងតាំងក្នុងឆ្នាំ២០០១។

ជាមួយគ្នានេះដែរ ក្នុងខែកញ្ញា ឆ្នាំនេះ យើងនឹងមាននិស្សិតទេវវិទ្យាល័យ ៣នាក់ រៀនឆ្នាំទី២ និង២នាក់ រៀនឆ្នាំទី៣ ហើយយើងនឹងមានម្នាក់ ឬ២នាក់ទៀត ចូលរៀនក្នុងឆ្នាំទី១។

គេទទួលអប់រំមានរយៈពេល ៦ឆ្នាំ ដោយមានសាស្ត្រាចារ្យជាបូជាចារ្យសាសនទូតជាច្រើន បានជួយខិតខំបង្រៀនមេរៀននានាជាភាសាខ្មែរដល់និស្សិតទាំងអស់ ដែលជាបេសកកម្មដើម្បីកសាងព្រះសហគមន៍នៅប្រទេសកម្ពុជា។

យើងក៏មិនភ្លេចផងដែរសាលាអប់រំជំនឿគ្រីស្តបរិស័ទ សន្តយ៉ូស្វីន ជារៀងរាល់ថ្ងៃសុក្រនិងថ្ងៃសៅរ៍ ក្នុងខែនីមួយៗ យុវជនយុវនារី ៥០នាក់ ដែលទទួលអគ្គសញ្ញាជ្រមុជទឹកហើយ បានមកទទួលការអប់រំអំពីទេវវិទ្យា អំពីជីវិតខាងវិញ្ញាណ អំពីព្រះគម្ពីរប្រវត្តិសាស្ត្រព្រះសហគមន៍ច្បាប់ព្រះសហគមន៍និងទស្សនៈអប់រំរបស់ព្រះសហគមន៍កាតូលិកអំពីការបម្រើសង្គម។ ពួកគេមានជំនឿកាន់តែមាំមួនឡើងៗ និងក្លាយជាសាក្សីអំពីសេចក្តីសង្ឃឹមយ៉ាងពិតប្រាកដដែលមានក្នុងជីវិតរបស់គេ។

ព្រះសហគមន៍របស់យើងកំពុងរីកចម្រើនឡើងប្រកបដោយសេចក្តីក្លាហាន និងការទទួលខុសត្រូវ!

នៅថ្ងៃព្រះហស្បត្តិ៍ យើងមានប្រារព្ធពិធីអធិដ្ឋានពេញមួយយប់សម្រាប់ការត្រាស់ហៅលើកទី៤០។ យើងមានជំនឿយ៉ាងមាំថា ព្រះអម្ចាស់នៃយើងពិតជាព្រះសណ្តាប់លឺពាក្យអង្វររបស់អ្នកដែលទូលសុំព្រះអង្គ។

នៅខែកក្កដា និងខែសីហានេះ យើងនឹងមានព្រឹត្តិការណ៍សំខាន់មួយចំនួនដូចជា៖ ពីថ្ងៃទី ២៤ - ៣១ ខែកក្កដា ឆ្នាំ២០១៥ ដំណើរទស្សនកិច្ចសិក្សារបស់សិស្សសាលាសន្តយ៉ូស្វីនទាំងអស់ នៅប្រទេសហ្វីលីភីន។ ថ្ងៃទី១០-១៦ ខែសីហា មានទិវាយុវជនកាតូលិកឡាវ-កម្ពុជា នៅប្រទេសកម្ពុជា។ ថ្ងៃទី ២០-២៣ ខែសីហា ឆ្នាំ ២០១៥ មានកម្មវិធីបោះជំរុំសម្រាប់ការត្រាស់ហៅនៅក្រុងព្រះសីហនុ។ ព្រឹត្តិការណ៍អស់នេះ ជាពេលវេលាពិសេសសម្រាប់ជួបជាមួយព្រះជាម្ចាស់ និងដើម្បីកសាងភាតរភាពរវាងគ្នានឹងគ្នាឲ្យកាន់តែមាំមួនឡើង។

សូមព្រះជាម្ចាស់ប្រទានពរដល់បងប្អូន! សូមបងប្អូនបានប្រកបដោយអំណរសប្បាយជានិច្ចពីព្រះជាម្ចាស់!

**អូលីវីយេ ស្មឺតអឺស្លែរ**
**អភិបាលភូមិភាគភ្នំពេញ**

# Apostolic Vicariate of Phnom Penh

## Bishop Olivier's Letter

## On Saturday, June 27, 2015, our Vicariate had the great joy of welcoming our new diocesan priest, Father Peter Sok Na!

Dear Bothers and Sisters

We thank God for the gift of Father Peter Sok Na and we ask the Lord to bless his ministry of service and love to the brothers and sisters in the Southern Pastoral Sector of Phnom Penh and indeed to all who seek the light of peace and mercy in their broken lives.

So now the Vicariate of Phnom Penh has three local priests, with Fathers Un Son and Suong Hangly who were ordained in 2001.

And in September of this year, we will have three seminarians in the second year and two in the third year of their studies. And certainly there will be one or two in the first year.

Their formation is part of a six-year cycle in which many missionary priest teachers make themselves available to teach in the Cambodian language. This is a vital service for building up the local church.

We also cannot forget our St. Justin School of Faith for the formation of the laity. Every month, on two Fridays and Saturdays, fifty baptized adults come together for formation in theology, spirituality, history, bible, ethics, and the social doctrine of the church. They strengthen their faith as they search for God and they become strong witnesses of the Hope that is in them.

This is our church, growing with responsibility and courage!

On Thursday we had the 40$^{th}$ night of prayer for vocations, believing that the Lord truly hears the prayers of those who implore him.

In July and August we will see many gatherings with our young people. Of special note is the trip of the St. Justin School to the Philippines from 24 to 31 July. Then there is the Laos/Cambodia Youth Day from 10-16 August here in Cambodia, and the Vocations Camp from August 20 to 23 in Sihanoukville. These are special moments to meet the Lord and build a more fraternal world.

God bless you and keep you in his joy!

+Olivier SCHMITTHAEUSLER
Apostolic Vicar of Phnom Penh

# លោកអភិបាលអូលីវីយេ ជំរុញឲ្យស្រឡាញ់ លើកលែងទោស និងបង្ហាញមេត្តាករុណា

លោកអភិបាលអូលីវីយេ ឆ្មីតអឺស្លែរ បានធ្វើអគ្គសញ្ញាលាបថ្វាសជូនដល់គ្រីស្តបរិស័ទចំនួន៣៣នាក់ ក្នុងឱកាសបុណ្យលើកតម្កើងព្រះកាយ និងព្រះលោហិតព្រះយេស៊ូ នៅព្រះវិហារសន្តីម៉ារីម៉ាដាឡា(ស្វាយប៉ាក) ដោយមានគ្រីស្តបរិស័ទ ប្រមាណជា៣០០នាក់ រួមជាមួយលោកប៉ូល រឿង ឆ័ត្រសិរី បូជាចារ្យទទួលខុសត្រូវព្រះសហគមន៍ នេះនាព្រឹកថ្ងៃទី៧ មិថុនា។



គ្រីស្តបរិស័ទដែលទទួលអគ្គសញ្ញាលាបថ្វាសនៅស្វាយប៉ាក-រូបថត៖ សុធីរិទ្ធ

លោកអភិបាលអូលីវីយេឆ្មីតអឺស្លែរបានមានប្រសាសន៍ថា៖"យើងមានតួនាទីដ៏អស្ចារ្យដើម្បីប្រកាសដំណឹងល្អដល់មនុស្សទាំងអស់ គឺប្រកាសពីវត្តមានព្រះជាម្ចាស់ដែលមាននៅក្នុងជីវិត ព្រោះយើងបានផ្សារភ្ជាប់ជាមួយព្រះវិញ្ញាណដ៏វិសុទ្ធនិងព្រះយេស៊ូ។"លោកអភិបាលបន្តថាកិច្ចការនេះត្រូវបំពេញដោយចិត្តស្រឡាញ់ ចេះលើកលែងទោស និងបង្ហាញធម៌មេត្តាករុណា ដែលនាំឲ្យយើងស្គាល់ពីវត្តមានរបស់ព្រះយេស៊ូពិតប្រាកដ។

រីឯយុវជនស្វាយប៉ាកក្នុងវ័យ២០ឆ្នាំ សេងហួន ដែលជាបេក្ខជនម្នាក់ក្នុងចំណោម៣៣នាក់ បានប្រាប់ថាបន្ទាប់ពីថ្ងៃនេះទៅនឹងព្យាយាមបំពេញតួនាទីជាគ្រីស្តបរិស័ទ ដោយធ្វើជាមនុស្សល្អចំពោះអ្នកដទៃ តាមរបៀបនៃការបង្ហាញសេចក្តីស្រឡាញ់ក្នុងព្រះសហគមន៍និងសង្គមទៅតាមរយៈក្រុមផ្សេងៗ ដូចជាក្រុមកាយឫទ្ធិជាដើម។

អគ្គសញ្ញាលាបថ្វាសជាពិធីមួយដើម្បីឲ្យបំពេញបន្ថែមលើអគ្គសញ្ញាជ្រមុជទឹក ដែលណែនាំឲ្យក្លាយជាគ្រីស្តបរិស័ទពេលលក្ខណៈ ដោយទទួលកម្លាំងពីព្រះវិញ្ញាណដ៏វិសុទ្ធ។ គ្រីស្តបរិស័ទ ដែលទទួលអគ្គសញ្ញាលាបថ្វាសទាំង ៣៣រូប មកពីព្រះសហគមន៍៣ដូចជាសែនសុខព្រែកតាទែន និងស្វាយប៉ាក៕

ដាលីស

## Bishop Olivier fosters Love, Forgiveness and Kindness

On the morning of $7^{th}$ June 2015 Rt. Rev. Olivier Schmitthaeusler, the bishop of the Apostolic Vicariate of Phnom Penh Celebrated and officiated at the Sacrament of Confirmation for 33 candidates. He was assisted by Fr. Paul Chatsirey Roeung the parish priest during the feast of promoting the glory of the Body and Blood of Jesus at St. Mary Madalen's Church in Svay Pak. The confirmation ceremony was witnessed by 300 parishioners.

Bishop Olivier said: "We have wonderful roles in proclaiming the Good News to all humans –the proclamation of God's presence in life because we are united to the Holy Spirit and Jesus. These works are to be done with love, forgiveness and expression of kindness that lead us to know the true presence of Jesus."

A 20-year-old youth Seng Huon, one of the 33 confirmands told that after today he would try to fulfill his role by acting as a Catholic by being a good person to other people by expressing love within the Church and society.

The Sacrament of Confirmation is administered with the anointing with Holy Oil by the Bishop on those who have been baptized. The ritual enables full out-pouring of Grace by the Holy Spirit, just as God poured out His Spirit on the Apostles during the feast of Pentecost. This Sacrament is needed for one to be a full member of the Catholic Church. The 33 confirmed candidates came from the three parishes–SenSok, Prek Taten and Svay Pak.

# បុណ្យរំឭកព្រះបេះដូងព្រះយេស៊ូនៅព្រះសហគមន៍កោះនរា

ព្រះសហគមន៍កោះនរានៃមណ្ឌលសកម្មភាពភ្នំពេញខាងត្បូង បានប្រារព្ធពិធីបុណ្យរំឭកដល់ព្រះបេះដូងព្រះយេស៊ូ ដែលជាឧបការីនៃព្រះសហគមន៍ ក្រោមអធិបតីភាពលោកអភិបាលអូលីវីយេឆ្មីតអឺស្លែរនិងលោកបូជាចារ្យទាំងអស់ដែលមានបន្ទុកដឹកនាំព្រះសហគមន៍កាតូលិកនៃមណ្ឌលសកម្មភាពនេះរួមជាមួយគ្រីស្តបរិស័ទប្រមាណជាង៤០០នាក់។

កម្មវិធីនេះប្រព្រឹត្តទៅនៅព្រឹកថ្ងៃទី១៤មិថុនា ដោយមានការអធិដ្ឋានដង្ហែរូបសំណាកព្រះបេះដូងព្រះយេស៊ូជាមួយចម្រៀងលើកតម្កើងព្រះជាម្ចាស់យ៉ាងឱឡារិក ជុំវិញព្រះវិហារចំនួន៣ជុំ ដើម្បីរំឭកដល់សេចក្តីស្រឡាញ់ដ៏ធំធេងរបស់ព្រះយេស៊ូរហូតបូជាព្រះជន្មសម្រាប់មនុស្សលោក។

លោកអភិបាលអូលីវីយេ បានមានប្រសាសន៍ថា៖ ព្រះបេះដូងរបស់ព្រះយេស៊ូ គឺជាព្រះហឫទ័យនៃសេចក្តីស្រឡាញ់។ លោកបានបន្តណែនាំគ្រីស្តបរិស័ទទាំងអស់ឲ្យខិតខំរស់នៅ ស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺធ្វើយ៉ាងណាឲ្យព្រះជាម្ចាស់សប្បាយព្រះទ័យ ដោយកែប្រែចិត្តគំនិតជឿលើដំណឹងល្អ និងខិតខំអនុវត្តតាមព្រះបន្ទូលព្រះជាម្ចាស់ និងទៅជាព្រះកាយព្រះយេស៊ូទាំងកម្លាំងកាយចិត្ត ដើម្បីជាសាក្សីនៃសេចក្តីស្រឡាញ់របស់អង្គ។

លោកខួនអាប្រាហាំ ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍នេះបានឲ្យដឹងថា៖ ព្រះសហគមន៍ក៏មានក្រុមបេះដូងព្រះយេស៊ូ ដែលតែងតែយកចិត្តទុកដាក់អធិដ្ឋាននិងមានសកម្មភាពមេត្តាករុណា។ មិនតែប៉ុណ្ណោះ អ្វីដែលសំខាន់ជាងគេគឺចេះរស់នៅតាមព្រះហឫទ័យព្រះជាម្ចាស់ គឺចេះមានទំនាក់ទំនងល្អជាមួយគ្នា ដោយចិត្តស្រឡាញ់របស់ព្រះយេស៊ូ និងដោយនឹកឃើញដល់អ្នកដទៃ ដោយបង្កើតទំនាក់ទំនងថ្មីជាមួយពួកគេ ដោយសេចក្តីស្រឡាញ់ គឺបន្តសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ជាមួយអ្នកដទៃ៕

ដាលីស

លោកអភិបាល និងគ្រីស្តបរិស័ទគោរពព្រះបេះដូងព្រះយេស៊ូ -រូបថត៖ សុធីរិទ្ធ



## Celebration of the feast of the Sacred Heart of Jesus

Koh Noria Church in the pastoral sector of Southern Phnom Penh, marked the celebration of the Sacred Heart of Jesus, the patron Saint of the Church with a special event. The celebration rite was officiated by Rt. Rev. Olivier Schmitthaeusler, the Bishop of the Apostolic Vicariate of Phnom Penh together with priests in the sector. The occasion was witnessed by more than 400 parishioners.

The feast took place last 14th June where the statue of Jesus was carried in procession around the church three times as prayers and hymns were recited and sung praising God.

Bishop Olivier said, the Sacred Heart of Jesus is the Will of love. Hence, he instructed all the parishioners to try hard to live their lives according to the Will of God. Do whatever they can to please God. Have conversion of heart by believing the Good News and try hard to follow the Word of God and to become the Body of Jesus with strength in order to bear witness of the love of Jesus.

Fr. Abraham Khun the parish priest said that the parish also has a devotional group dedicated to the Sacred Heart of Jesus. This group always focuses their attention on prayer and charitable works. Not only that, what is more important is living a life according to the Will of God, having healthy relationships with one another with love of Jesus by creating a new relationship with them.

# អគ្គសញ្ញាលាបថ្វាសឲ្យគ្រីស្តបរិស័ទចេះដាក់ខ្លួន និងសម្តែងមេត្តាករុណា



*គ្រីស្តបរិស័ទទទួលអគ្គសញ្ញាលាបថ្វាសពីលោកអភិបាល-រូបថត៖ សុធីរិទ្ធ*

គ្រីស្តបរិស័ទចំនួន៣៣នាក់ ទទួលអគ្គសញ្ញាលាបថ្វាសនៅព្រះវិហារព្រះបេះដូងព្រះយេស៊ូ (ព្រះសហគមន៍កោះនរា)កាលពីថ្ងៃទី១៤ខែមិថុនា ឆ្នាំ២០១៥នេះក្រោមអធិបតីភាព លោកអភិបាលអូលីវីយេ ជ្មីតអឺស្លែរ និងលោកបូជាចារ្យនៃមណ្ឌលសកម្មភាពភ្នំពេញខាងត្បូង រួមជាមួយគ្រីស្តបរិស័ទជាង៤០០នាក់។

បេក្ខជន ប៉ូឡូ ជាសុខា មកពីព្រះសហគមន៍តួតាំងបានឲ្យដឹងថា៖ អគ្គសញ្ញាលាបថ្វាសនេះ ពិតជាសំខាន់សម្រាប់ខ្ញុំព្រោះថាខ្ញុំបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធមកបំភ្លឺចិត្តគំនិតនិងផ្តល់កម្លាំងកាយចិត្ត ដើម្បីប្រកាសដំណឹងល្អ អំពីព្រះជាម្ចាស់ដោយស្តាប់ព្រះបន្ទូល ចេះសម្តែងចិត្តមេត្តាករុណាចំពោះអ្នកឯទៀត និងចេះស្រឡាញ់គ្នាទៅវិញទៅមក "។

រីឯ លី វណ្ណា បានប្រាប់ផងដែរថា ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំគាត់ឲ្យចេះដាក់ខ្លួន មិនមានភាពអាត្មានិយម តែឲ្យយល់ពីអ្នកដទៃ។ លោកបន្តថា លោកនឹងខិតខំកសាងព្រះសហគមន៍ ដោយព្យាយាមស្រឡាញ់ព្រះយេស៊ូ គឺស្រឡាញ់បងប្អូនដទៃទៀត ព្រោះពួកយើងគឺជាគ្រួសារតែមួយ ក្នុងអង្គព្រះគ្រីស្ត។

អគ្គសញ្ញាលាបថ្វាស ជាពិធីមួយបន្ទាប់ពីអគ្គសញ្ញាជ្រមុជទឹក ដែលធ្វើឲ្យក្លាយជាគ្រីស្តបរិស័ទពេញលក្ខណៈ។ លោកអភិបាលអូលីវីយេ បានមានប្រសាសន៍លើកទឹកចិត្តគ្រីស្តបរិស័ទទាំងអស់ជាពិសេសបេក្ខជនដែលទើបតែទទួលអគ្គសញ្ញាលាបថ្វាសទាំងនោះថា៖ ព្រះជាម្ចាស់បានជ្រើសរើសយើងទាំងអស់គ្នា ដែលជាមនុស្សតូចតាច ដើម្បីធ្វើឲ្យគម្រោងការរបស់ព្រះអង្គបានរីកចម្រើនឡើង គឺមានន័យថា យើងជាមនុស្សតូចតាច តែយើងមានសម្ថភាពមកពីព្រះជាម្ចាស់ ដើម្បីបង្កើតសង្គមថ្មី ដែលជាព្រះរាជ្យព្រះជាម្ចាស់ ដោយយកព្រះនាងម៉ារីជាគំរូ គឺត្រូវទុកចិត្តលើព្រះជាម្ចាស់មានការអត់ធ្មត់និងដាក់ខ្លួនជាអ្នកបម្រើដោយស្រឡាញ់គ្នាទៅវិញទៅមក ដែលជាកេរ្តិ៍មរតក ដែលព្រះយេស៊ូបានទុកឲ្យយើង។

លោកបូជាចារ្យ ខូន អាប្រាហាំ ជាអ្នកទទួលខុសត្រូវព្រះសហគមន៍នេះបានឲ្យដឹងថា៖ បេក្ខជនដែលទទួលអគ្គសញ្ញាលាបថ្វាសនៅថ្ងៃនេះ ព្រះសហគមន៍និងប្រមូលពួកគាត់ឲ្យជិតស្និទ្ធិជាមួយព្រះស៊ូ តាមរយៈសកម្មភាពរបស់ព្រះសហគមន៍។

បេក្ខជនទាំង៣៣នាក់នេះ មកពីព្រះសហគមន៍២កន្លែងនៃមណ្ឌលសកម្មភាពភ្នំពេញខាងត្បូង គឺព្រះសហគមន៍តួតាំង ៩នាក់ និងព្រះសហគមន៍កោះនរាចំនួន២៤នាក់៕ ដាលីស

## Confirmation Leads to a Life of Humility and Charity

Thirty three Catholics received the Sacrament of Confirmation last 14th June at the Sacred Heart of Jesus Church in Koh Noria. The Confirmation rite was officiated by Rt. Rev. Olivier Schmitthaeusler, the Bishop of the Apostolic Vicariate of Phnom Penh together with priests in the pastoral sector of Southern Phnom Penh. The occasion was witnessed by more than 400 parishioners.

Bishop Olivier encouraged all the Catholics, especially those who have just been confirmed, to help build the Kingdom of God. He said: "God has chosen all of us, who are just small and insignificant people, in order for His Mystery to grow. Yes, we are just little and simple people but we have the capacity bestowed on us by God to create a new society, that is the Kingdom of God -- by following the example of Mary, our model. So, be patient and humble in serving one another with love -- that is the inheritance that Jesus bequeathed to us."

PoLo Chea Sokhar, one of those confirmed and who is from St. Maria Church in Tutaing, said: "The Sacrament of Confirmation is really crucial for me because I received the Holy Spirit who now enlightens my mind and also gives me physical strength to proclaim the Good News of God which comes to us when we listen to the Word, do charitable works and love one another."

Ly Vanna said: "The Holy Spirit inspires me to be humble, selfless and mindful of others." Vanna will try hard to build the Church by loving Jesus as well as others, "because we are one family in the Person of Christ."

Fr. Abraham Khun the parish priest, said that those who received the Sacrament of Confirmation, were now allowed to join the group of the Sacred Heart of Jesus. It is hoped that it will draw them closer to Jesus. The confirmands came from two parishes in the pastoral sector of Southern Phnom Penh – 9 candidates from TuTaing Church and 24 others from Koh Noria Church.

The Sacrament of Confirmation is performed with anointing of sacred chrism by the Bishop on those who have been baptized in order to strengthen their baptismal grace.

# កុមារ២៦នាក់ ទទួលព្រះកាយលើកដំបូង

កុមារា កុមារី ចំនួន២៦នាក់ ទទួលអគ្គសញ្ញាព្រះកាយ ព្រះគ្រីស្តលើកទីមួយ នាព្រឹកថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥ នេះ ក្នុងឱកាសបុណ្យរំឭកសន្តសិលា និងសន្តប៉ូល ដែលជាសរសរគ្រឹះនៃព្រះសហគមន៍ នៅព្រះសហគមន៍កាតូលិក សំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ដោយមានលោកស្រីប្រាមុង វីរៈជ័យ ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍ ជាប្រធានអភិបូជា និងចូលរួមដោយគ្រីស្តបរិស័ទចំនួន២៣០នាក់។ កុមារទាំងនេះមានអាយុចាប់ ពី១០ដល់១៥ឆ្នាំ បានទទួលអប់រំជំនឿអស់រយៈពេលមួយឆ្នាំបួនខែ ហើយពួកគាត់មានអំណរសប្បាយនិងរីករាយ យ៉ាងខ្លាំងក្នុងការទទួលអគ្គសញ្ញានាថ្ងៃនេះ។

កុមារី ឈួន ចន្ធី បានឲ្យដឹងថា៖ ខ្ញុំសប្បាយណាស់ពេលបានទទួលព្រះកាយលើកដំបូង ឥឡូវខ្ញុំមានព្រះយេស៊ូគង់នៅជាមួយ ហើយខ្ញុំស្រឡាញ់ព្រះយេស៊ូណាស់។

រីឯកុមារា លី សំណាងវិញ គាត់បានឲ្យដឹងថា៖ ខ្ញុំត្រេកអរណាស់ ពេលបានទទួលព្រះកាយព្រះយេស៊ូ ខ្ញុំនិងខិតខំរស់នៅឲ្យសមរម្យ ក្នុងឋានជាបុត្រធីតារបស់ព្រះជាម្ចាស់ ខ្ញុំព្យាយាមប្រព្រឹត្តអំពើល្អ ជៀសវាងអំពើអាក្រក់ ដើម្បីកុំឲ្យព្រះយេស៊ូជាទីស្រឡាញ់របស់ខ្ញុំព្រួយចិត្ត។

ក្នុងធម្មទេសនា លោកបូជាចារ្យបានមានប្រសាសន៍អប់រំគ្រីស្តបរិស័ទក្នុងឱកាសបុណ្យនេះ ឲ្យយកតម្រាប់តាមគំរូរបស់សន្តសិលា និងសន្តប៉ូល។ លោកបន្តថា ទោះបីសន្តសិលាបានបដិសេធមិនស្គាល់ព្រះយេស៊ូ តែក្រោយមកគាត់ក្លាយជាអ្នកមានជំនឿមាំមួន ដឹកនាំព្រះសហគមន៍របស់ព្រះអង្គ រីឯសន្តប៉ូល មុនគាត់បានបៀតបៀនគ្រីស្តបរិស័ទយ៉ាងខ្លាំង ប៉ុន្តែពេលជួបព្រះយេស៊ូ គាត់ផ្លាស់ប្តូរទាំងស្រុងក្លាយជាគ្រីស្តទូតមួយរូប ដែលស៊ូប្តូរជីវិតចំពោះការប្រកាសដំណឹងល្អ ដល់មនុស្សគ្រប់ជាតិសាសន៍។ ហេតុនេះ លោកសូមបងប្អូន ជាពិសេសកូនៗដែលបានទទួលព្រះយេស៊ូថ្ងៃនេះ ត្រូវផ្លាស់ប្តូរជីវិតរបស់ខ្លួន ដើម្បីព្រះគ្រីស្ត និងដើម្បីដំណឹងល្អរបស់ព្រះអង្គ។ លោកសង្កត់ធ្ងន់ថា៖ សូមកុំទទួលព្រះគ្រីស្ត តែក្នុងព្រះវិហារប៉ុណ្ណោះ ប៉ុន្តែសូមនាំព្រះកាយ របស់ព្រះអង្គចេញពីព្រះវិហារ គឺឲ្យព្រះអង្គចូលក្នុងជីវិត ប្រចាំថ្ងៃរបស់បងប្អូន ដើម្បីឲ្យមនុស្សទាំងអស់ ដែលមិនទាន់ស្គាល់ព្រះអង្គ បានឃើញវត្តមានរបស់ព្រះគ្រីស្តក្នុងការរស់នៅ ប្រចាំថ្ងៃរបស់បងប្អូន។

ព្រះសហគមន៍កាតូលិកសំរោងធំ បានចាប់ផ្តើមនៅឆ្នាំ១៩៨២ ដោយមានគ្រីស្តបរិស័ទ ចំនួន២ឬ៣គ្រួសារ មករស់នៅភូមិព្រែកត្រែង ឃុំសំរោងធំ។ តាមរយៈសកម្មភាពនានា នៃការប្រកាសដំណឹងល្អ សព្វថ្ងៃនេះមានរហូតដល់៨៣គ្រួសារ គឺចំនួន៤២៨នាក់៕ Br សំណាង

*កុមារទាំង២៦នាក់ដែលបានទទួលព្រះកាយព្រះគ្រីស្តលើកដំបូង -រូបថត៖ DR*



# 26 Children Receive First Holy Communion

Twenty six children received their First Holy Communion on the morning of June $28^{th}$ 2015 during the feast of Saints Peter and Paul at the church of the Immaculate Conception in Somrong Thom district, Kandal province's KienSvay district. Fr. Sri Pramong Vireak Chhey the parish priest celebrated the Eucharist and the event was witnessed by many parishioners.

The Twenty six children's ages ranged from 10 to 15 and were educated in the Catholic faith for a period of four months. The children were very delighted at receiving the Sacrament of Holy Communion. One child, Chhuon Chanthy said: "I am very happy to receive Holy Communion and now Jesus dwells within me and I do love Him."

Another child Ly Samnang said: "I feel the joy of receiving the Body of Jesus and I will try hard to live a proper life as a son of God, I will try to do good deeds by avoiding bad actions and not hurt Jesus."

In his homily, the priest instructed the parishioners to follow and imitate the exemplary models of saints Peter and Paul. He continued by saying that even though St. Peter refused to know Jesus but subsequently became a strong leader of the Church. Saint Paul who once persecuated Christians. However, when he encountered Jesus he had changed completely and became an apostle sacrificing his life by proclaiming the Good News of God to all the nations. "Therefore you children, who received Jesus Today have to change your lives for Christ and proclaim the Good News."

The priest stressed: "Please don't receive Christ only in spirit but take His Body out of the church to the world and let Him enter your day-to-day life so that all the people who don't know Him will feel His presence in their daily lives."SomrongThom Church started in 1982 with two or three Catholic families living in Prek Treng village, Somrong Thom commune. But through its pastoral activities of proclaiming of the Good News, there are now up to 83 families with the total number of 428 parishioners.

# ទស្សនកិច្ចផ្លូវការរបស់លោកអភិបាលអូលីវីយេ នៅមណ្ឌលសកម្មភាពព្រះសីហនុ

លោកអភិបាល អូលីវីយេ ឆ្មីតអឺស្លែរ បានបំពេញទស្សនកិច្ចជាផ្លូវការ ទៅកាន់ព្រះសហគមន៍កាតូលិកនៃមណ្ឌលសកម្មភាពព្រះសីហនុចាប់ពីថ្ងៃទី១៧-២១ខែមិថុនា។

ដំណើរទស្សនកិច្ចនេះគឺជាពេលវេលា ដែលលោកអភិបាលសួរសុខទុក្ខបងប្អូនគ្រីស្តបរិស័ទ ស្តាប់នូវសេចក្តីរាយការណ៍ផ្សេងៗ អំពីសកម្មភាពរបស់ព្រះសហគមន៍ក្នុងការប្រកាសដំណឹងល្អ និងសម្តែងមេត្តាករុណា ស្វែងយល់ពីជីវភាពរបស់គ្រីស្តបរិស័ទនិងស្តាប់សំណូមពរនានាពីគណៈកម្មការព្រះសហគមន៍ លោកបូជាចារ្យ ដូនជី យុវជនយុវនារីនិងសេចក្តីត្រូវការរបស់ក្រុមកុមារជាដើម។

ក្នុងដំណើរទស្សនកិច្ចនេះ លោកអភិបាលបានចុះទៅព្រះសហគមន៍មួយចំនួនមាន៖ ព្រះសហគមន៍ត្រែងត្រយឹង កោះកុង ស្រែអំបិល ទឹងតាព្រហ្ម កោះខ្យង និងក្រុងព្រះសីហនុ ដោយមានធ្វើអគ្គសញ្ញាលាបថ្វាសដល់បេក្ខជនចំនួន២៤រូប នៅទីនោះផងដែរ។

នៅតាមកន្លែងនីមួយៗតំណាងគ្រីស្តបរិស័ទបានរាយការណ៍ជូនលោកអភិបាលអំពីប្រវត្តិព្រះសហគមន៍ សកម្មភាពលើកតម្កើងព្រះជាម្ចាស់ ការអប់រំបន្តជំនឿ កិច្ចការសង្គហៈជាដើម។ ជាងនេះទៅទៀត គេក៏មានជំរាបជូនលោកនូវបញ្ហាលំបាកមួយចំនួន និងបានលើកជាសំណូមពរជូនលោកផងដែរ។

ក្រោយពីបានទៅដល់ទីកន្លែងនីមួយៗជាក់ស្តែង និងឃើញសភាពជីវិតនៃព្រះសហគមន៍និងស្តាប់ដោយយកចិត្តទុកដាក់លោកអភិបាលអូលីវីយេ បានលើកទឹកចិត្តគ្រីស្តបរិស័ទលោកបូជាចារ្យនិងបព្វជិតបព្វជិតាក្នុងធម្មទេសនាបិទដំណើរទស្សនកិច្ចយ៉ាងនេះថា៖ " សូមបងប្អូនថែរក្សាក្រុមគ្រីស្តបរិស័ទ "។ លោកបន្តថា ទាំងអស់គ្នាមាន តួនាទីណែនាំ គ្នាទៅវិញទៅមក ឲ្យយកចិត្តទុកដាក់អធិដ្ឋាន ឲ្យយកចិត្តទុកដាក់អប់រំជំនឿនិងទទួលការអប់រំជំនឿ។លោកក៏ជំរុញឲ្យមានការសហការគ្នាយ៉ាងពិតប្រាកដ រវាងមនុស្សចាស់និងយុវជន ដើម្បីកសាងព្រះសហគមន៍។ជាងនេះទៅទៀតធ្វើយ៉ាងណា ណែនាំឲ្យក្រុមគ្រួសារនីមួយៗ ឲ្យមានការរីកចម្រើន ព្រោះគ្រួសារជាគោលព្រះសហគមន៍។

ចំពោះគ្រីស្តបរិស័ទ ដែលភាគច្រើនមិនបានមកវិហារ លោកអភិបាល លើកទឹកចិត្តដល់គ្រីស្តបរិស័ទ ដែលរឹងមាំក្នុងជំនឿ " ឲ្យចេញទៅ " សួរសុខទុក្ខគេ លើកទឹកចិត្តគេ ណែនាំគេ ឲ្យយល់អំពីសារៈសំខាន់ក្នុងការនៅជាមួយព្រះយេស៊ូ និងត្រូវមានចិត្តអត់ធ្មត់ជួយបងប្អូនទាំងនោះឲ្យយល់ពីជំនឿពិតប្រាកដ។

ក្នុងពេលនោះដែរលោកអភិបាលលើកទឹកចិត្តឲ្យបងប្អូនបំពេញតួនាទីរបស់ខ្លួនជាគ្រីស្តបរិស័ទ ដែលជាបេសកកម្មសំខាន់បំផុតក្នុងជីវិត ជាគ្រីស្តបរិស័ទ ជាសាសនទូតគឺ "ប្រកាសដំណឹងល្អ " អំពីព្រះយេស៊ូ គឺប្រកាសអំពីវត្តមានរបស់ព្រះអង្គក្នុងរបៀបរស់នៅប្រចាំថ្ងៃរបស់ខ្លួន តាមរយៈការចែករំលែកសេចក្តីស្រឡាញ់ ការបម្រើបងប្អូនក្រីក្រ អ្នកជំងឺ អ្នកតូចតាច អ្នកដែលគេមិនរាប់រក និងប្រកាសតាមរយៈទំនាក់ទំនងប្រចាំថ្ងៃរបស់យើងជាដើម។

លោក លេង ហុង ជាគ្រូអប់រំជំនឿនៅព្រះសហគមន៍ត្រែងត្រយឹងឲ្យដឹងថា ដំណើរទស្សកិច្ចនេះពិតជាមានសារៈសំខាន់ណាស់ ដែលលោកអភិបាលមកស្គាល់កន្លែងយើង និងជាកម្លាំងដ៏ពិសេស ដើម្បីលើកទឹកចិត្តយើងគ្រប់គ្នា ក្នុងការបន្តមុខងាររបស់ខ្លួនឲ្យកាន់តែប្រសើរឡើង។

ដូនជី សាលវេ មកពីក្រុមបងស្រី ដូមីនីកូ បាននិយាយថា វត្តមានរបស់អភិបាល ពិតជាកម្លាំងពិសេសដើម្បី ជំរុញនិងលើកទឹកចិត្តយើង ឲ្យធ្វើការកាន់តែខ្លាំងឡើងៗ ក្នុងការប្រកាសដំណឹងល្អដល់បងប្អូន៕

សុវណ្ណា


លោកអភិបាលទស្សនកិច្ចនៅព្រះសហគមន៍កោះខ្យង-រូបថត៖ លី សុវណ្ណា


កិច្ចប្រជុំគណកម្មការក្នុងមណ្ឌលសកម្មភាពកំពង់សោម-រូបថត៖ សុធីរិទ្ធ

# Visit To Sihanouk ville



ដំណើរទស្សនកិច្ចនៅព្រះសហគមន៍ត្រែងត្រយឹង-រូបថត៖ លី សុវណ្ណា



ដំណើរទស្សនកិច្ចនៅព្រះសហគមន៍ស្រែអំបិល-រូបថត៖ លី សុវណ្ណា

Rt. Rev. Olivier Schmitthaeusler, the bishop of the Apostolic Vicariate of Phnom Penh made his Pastoral visit to the pastoral sector in Sihanouk ville parish from 17th to 21st June 2015.

The Pastoral Visit is a time when the bishop visits parishioners and listens to reports of the pastoral activities of the Church in terms of the proclamation of Good News and charitable works and even learns to underst and the live lihoods of the parishioners and hear their requests made by the committee of the Church, which includes priests, nuns, youths and needs for children.

At each place, representatives of the parishioners reported to the bishop about the history and the pastoral activities of the parishes and the works of charity and so on. The representatives also told the bishop about certain problems and made some requests to him.

Having seen the real pastoral life of the parishes, the bishop offered encouraging remarks in his homily: "Please take care of flock." The bishop continued by saying that everybody had a role to play in the growth of the sector by instructing one another and to pay attention to prayer and faith education. He urged a true cooperation between elderly and young people in order to build up the Church and to do whatever they can to guide each family to make progress as the family is the foundation of the Church.

For most of the parishioners who have failed to come to church the bishop encouraged the Catholics who have a firmer faith to go out and visit them, encourage them, lead them to understand about the significance of walking with Jesus and have patience with them in order for them to understand their true faith.

The bishop also encouraged those people who fulfilled their roles as Catholics, which are the most important in Catholics' lives as missionaries –the proclaiming of the Good News of Jesus. "This is the proclamation of His presence of day-to-day way of life by sharing love, serving the poor, sick, those who are marginalized and rejected through our daily communications and so on."

Mr. Leng Hong, the catechist at Treng Trayeng Church said: "The Pastoral visit was of great importance since the bishop comes to know our place and it is a special strength to encourage all of us to further our commitment."

A nun Salve, who comes from the Missionary Religious of St. Dominic, said "That the presence of the bishop gives a special strength of mind by encouraging us to work more and more to spread the Good News to other people."

# អគ្គសញ្ញាលាបថ្វាសនៅព្រះសហគមន៍កាតូលិកកំពង់សោម



*លោកអភិបាលទ្រាបដៃលើបេក្ខជនដែលត្រូវទទួលអគ្គសញ្ញាលាបថ្វាស-រូបថត៖ លី សុវណ្ណា*

## Twenty four candidates Receive Sacrament of Confirmation

ព្រះសហគមន៍កាតូលិកមណ្ឌលសកម្មភាពកំពង់សោម បានរៀបចំកម្មវិធីអគ្គសញ្ញាលាបថ្វាស ជូនដល់បងប្អូនគ្រីស្តបរិស័ទចំនួន ២៤នាក់ ដើម្បីឲ្យពួកគេក្លាយជាគ្រីស្តបរិស័ទដ៏ពេញលក្ខណៈ។ ពីធីនេះធ្វើក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់លោកអភិបាលអូលីវីយេ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០១៥ នៅព្រះវិហារសន្តមីកាអែលក្រុងព្រះសីហនុ។

នៅក្នុងពិធីនោះផងដែរ លោកអភិបាលបានថ្លែងថា៖ ថ្ងៃនេះបងប្អូនបានទទួលអគ្គសញ្ញាលាបថ្វាសមានន័យថា បងប្អូនក្លាយជាគ្រីស្តបរិស័ទដ៏ពេញលក្ខណៈហើយ។ លោកក៏ពន្យល់ទៀតថា៖ អគ្គសញ្ញាលាបថ្វាស គឺជាឫទ្ធិអំណាច និងឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធដែលជាកម្លាំងក្នុងការចេញទៅប្រកាសដំណឹងល្អ ដូចក្រុមគ្រីស្តទូតពីដើម។

លោកបានសូមឲ្យគ្រីស្តបរិស័ទចេះរួមគ្នាជាមួយលោកបូជាចារ្យនិងបងស្រីទាំងអស់ខិតខំបម្រើព្រះសហគមន៍ឲ្យអស់ពីកម្លាំងកាយចិត្ត និងបង្ហាញសេចក្តីស្រលាញ់ ដែលព្រះយេស៊ូប្រទានឲ្យ ដោយយកចិត្តទុកដាក់រក្សាគ្នាទៅវិញទៅមក យកចិត្តទុកដាក់ក្នុងការអប់រំជំនឿដល់មនុស្សគ្រប់វ័យ និងរួមគ្នាសហការក្នុងការធ្វើកាងារផ្សេងៗក្នុងព្រះសហគមន៍ ។

យុវជន សុ រិទ្ធ បានឲ្យដឹងថា៖ ខ្ញុំពិតជាមានអំណរសប្បាយណាស់ដោយបានទទួលអគ្គសញ្ញាលាបថ្វាសនៅថ្ងៃនេះ ធ្វើឲ្យខ្ញុំបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីណែនាំខ្ញុំឲ្យមានសេចក្តីស្រឡាញ់ មានចិត្តមេត្តាករុណា ចេះចែករំលែក និងអត់ឱនឲ្យគ្នា។ បេក្ខជននេះប្រាប់ទៀតថា៖ ធម្មទេសនារបស់លោកអភិបាល ជួយខ្ញុំខាងជីវិតផ្លូវវិញ្ញាណថែមទាំងយល់កាន់តែច្បាស់ពីជីវិតគ្រីស្តបរិស័ទ និងមានជំនឿ មានចិត្តសង្ឃឹមលើព្រះយេស៊ូ៕ តូច ពឿន

St. Michael's parish in the pastoral sector of Kampong Som celebrated the Sacrament of Confirmation for 24 candidates in their parish. The Confirmation rite was officiated by Rt. Rev. Olivier Schmitthaeusler, the bishop of the Apostolic Vicariate of Phnom on 21st June 2015.

In his homily, the bishop stated that receiving the Sacrament of Confirmation meant that the confirmands will become full Catholics. He further said the Sacrament of Confirmation has the power and leverage of the Holy Spirit, which becomes the strength for going out to proclaim the Good News of God like the early apostles.

The bishop asked the parishioners to unite with all the priests and religious to makes efforts to serve the Church with all their strength of minds and souls expressing the love, which Jesus bestowed on us. He urged all to focus on faith education for the adults and cooperate with one another in the different pastoral life of the parish.

A youth So Rith said: "I am very pleased to receive the Sacrament of Confirmation today because I receive the Holy Spirit, who leads me to love, to show kindness, to share and forgive one another. The homily delivered by the bishop helps me spiritually and even made me understand clearly about the life of Catholics and hope in Jesus."

# លោកសិលា សុខ ណា ជាបូជាចារ្យជាតិកម្ពុជា ទី៨

ក្បួនដង្ហែយ៉ាងឱឡារឹក ជាមួយនិងសូរសម្លេងទំនុកតម្កើងអមដំណើរ លោកឧបដ្ឋាកសិលាសុខ ណា ចូលក្នុងវេទិកា ដើម្បីទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ ដែលជាអំណរសប្បាយរបស់ព្រះសហគមន៍កាតូលិកកម្ពុជា ជាពិសេសភូមិភាគភ្នំពេញ។ ពិធីនេះបានប្រព្រឹត្តទៅនៅព្រះវិហារសន្តយ៉ូសែបផ្សារតូចភ្នំពេញ នាព្រឹកថ្ងៃទី២៧ មិថុនា ២០១៥នេះ ដែលមានលោកអភិបាលអូលីវីយេ ជ្មឹតអីស្លែរ ជាអធិបតី និងមានការចូលរួមពីសំណាក់លោកអភិបាល និងបូជាចារ្យជាច្រើនរូប និងគ្រីស្តបរិស័ទជាងពីរពាន់នាក់។



លោកបូជាចារ្យ សិលា សុខ ណា

បន្ទាប់ពីក្បួនដង្ហែបានមកដល់វេទិការួចរាល់ លោកបូជាចារ្យ អ៊ុន ស៊ុន បានកោះហៅបេក្ខជន សិលា សុខ ណា ឲ្យបង្ហាញខ្លួននៅមុខគ្រីស្តបរិស័ទទាំងអស់។ បន្ទាប់មកលោកបូជាចារ្យ រ៉ូប៊ឺត ពិសេ ដែលជានាយកទេវវិទ្យាល័យ បានស្នើសុំលោកអភិបាលអូលីវីយេ ដោយអះអាងថាលោកសិលា សុខ ណា ពិតជាមានសម្ថភាពក្នុងការទទួលអគ្គសញ្ញាតែងតាំង ធ្វើជាបូជាចារ្យពិតប្រាកដមែន។ ជាមួយគ្នានេះដែរ លោកម៉ារីយ៉ូ ហ្គេហ្ស៊ី ជាតំណាងពេញសិទ្ធិរបស់លោកអភិបាលអូលីវីយេ បានឡើងប្រកាសជាសាធារណៈ អំពីគុណសម្បត្តិរបស់បេក្ខជន សុខ ណា ចាប់តាំងពីថ្ងៃដែលលោកបានស្គាល់ គឺបេក្ខជនរូបនេះ តែងយកចិត្តទុកដាក់ចំពោះមិត្តភាពជាមួយព្រះយេស៊ូ ដោយអធិដ្ឋាន ទទួលស្គាល់ពីវត្តមានរបស់ព្រះយេស៊ូនៅក្នុងជីវិត យកចិត្តទុកដាក់ជាមួយអ្នកក្រីក្រ ដោយយល់ថាអ្នកទាំងនោះជាតំណាងព្រះយេស៊ូដែលកំពុងលំបាកពិតមែន។លោកសុខណាបានយកចិត្តទុកដាក់អំពីពិធីបុណ្យ (អភិបូជា) ដោយស្ម័គ្រចិត្តជួយណែនាំក្រុមបម្រើអាសនៈ លោកតែងតែចាប់អារម្មណ៍ចំពោះអ្នកដែលស្វែងរកការត្រាស់ហៅឲ្យធ្វើជាបព្វជិត បព្វជិតា និងមានបំណងធ្វើសាសនទូត ដើម្បីប្រកាសដំណឹងល្អដល់បងប្អូនឯទៀតៗ។

ដោយយោងតាមអំណះអំណាង និងការស្នើសុំខាងលើ លោកអភិបាលបានប្រកាសជ្រើសរើស លោកសិលា សុខ ណា ឲ្យទទួលអគ្គសញ្ញាតែងតាំងបូជាចារ្យ ដោយមានការគាំទ្រពីព្រះយេស៊ូផងដែរ។ ក្នុងធម្មទេសនា លោកអភិបាលបានមានប្រសាសន៍ថា៖ នេះជាគំរោងការរបស់ព្រះជាម្ចាស់ និងផលផ្លែដែលកើតចេញពីការអធិដ្ឋាន និងគំរូរបស់បងប្អូន។

ថ្ងៃនេះលោក សុខ ណា លែងជាឧបដ្ឋាកទៀតហើយ គឺជាមិត្តសម្លាញ់។ លោកបញ្ជាក់ថា នេះមិនមែនជាពាក្យដែលចេញពីបបូរមាត់របស់លោកទេ តែជាព្រះបន្ទូលរបស់ព្រះយេស៊ូផ្ទាល់។ លោកបន្តថា ដោយសារអំណាចនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដោយសារការទ្រាបដៃ លោក សុខ ណា នឹងទៅជាបូជាចារ្យ ទៅជាមិត្តសម្លាញ់ដែលព្រះយេស៊ូបានជ្រើសរើស និងខ្ញុំខ្លួន សុខ ណា ឲ្យបូជាជីវិតរួមជាមួយព្រះយេស៊ូ ដើម្បីយើងទាំងអស់គ្នា



លោកបូជាចារ្យ ប្រ៊ុយណូ បំពាក់អាវជូនបូជាចារ្យថ្មី-រូបថត៖ សម្បត្តិ



លោកអភិបាល លោកបូជាចារ្យ និងគ្រីស្តបរិស័ទគោរពសន្តបុគ្គល-រូបថត៖ សម្បត្តិ



លោកបូជាចារ្យ សុខ ណា គោរពក្រុមគ្រួសារ-រូបថត៖ សុធីរិទ្ធ

ទទួលជីវិតថ្មី និងសុភមង្គលពិតប្រាកដ គឺមានន័យថាទទួលការសង្គ្រោះ ដែលជាអាថ៌កំបាំងរបស់បូជាចារ្យទាំងអស់ដែលខិតខំរស់នៅក្នុងជីវិតរបស់បូជាចារ្យ។ លោកអភិបាលក៏បាន ណែនាំគ្រីស្តបរិស័ទទាំងអស់ជាពិសេសលោកបូជាចារ្យថ្មី ដើម្បីចូលយ៉ាងជ្រៅជាជីវិតជាបូជាចារ្យ ដោយគោលដៅ៤សំខាន់ៗ គឺមានជំនឿ ដោយចាប់ពីពេលនេះតទៅលោក សុខ ណា លែងមានជីវិតជាឯកជនទៀតហើយ គឺលោកបូជាជីវិតជាសាធារណៈសម្រាប់ព្រះយេស៊ូ និងក្នុងព្រះយេស៊ូ តាមរយៈការបម្រើព្រះសហគមន៍ ដោយចិត្តស្មោះអប់រំបងប្អូនឯទៀតៗ ឲ្យទៅជាធ្លុងតែមួយជាមួយព្រះគ្រីស្ត និងជាគង្វាលដ៏សប្បុរសដើម្បី ឲ្យយើងទៅជាសេចក្តីស្រឡាញ់ដ៏ពេញលក្ខណៈសម្រាប់មនុស្សទាំងអស់។

លោកបន្តថា " ត្រូវដាក់ខ្លួន ដោយយកព្រះនាងម៉ារី សន្តយ៉ូសែប និងលោកយូហានបាទីស្ត អ្នកម្តាយតេរេសា ជាគំរូនៃជំនឿ ដែលដាក់ខ្លួនគ្រប់ពេលវេលា ដើម្បីបង្ហាញពីវត្តមានព្រះគ្រីស្ត និងឧបការគុណរបស់ព្រះជាម្ចាស់ដល់បងប្អូនឯទៀតៗ"។ ព្រមជាមួយគ្នានេះ ត្រូវមានចិត្តមេត្តាករុណាប្រណីសណ្តោស ដែលជារបៀបព្រះយេស៊ូលើកលែងទោស និងមើលអ្នកដែលពិបាកដោយចិត្តស្រឡាញ់របស់ព្រះអង្គ។ លោកបូជាចារ្យត្រូវបូជាសម្រាប់មនុស្សទាំងអស់ គឺមិនមែនសម្រាប់តែក្រុមមួយ ដែលយើងស្រឡាញ់យើង ស្គាល់យើងតែប៉ុណ្ណោះទេ។ លោកអភិបាលក៏បានផ្តាំផ្ញើដល់គ្រីស្តបរិស័ទទាំងអស់ ជាពិសេសដល់យុវជនយុវនារីឲ្យភ្ញាក់ស្មារតី ឆ្លើយតាមនឹងការត្រាស់ហៅ ដើម្បីឲ្យមានបព្វជិត បព្វជិតាយ៉ាងច្រើនក្នុងប្រទេសកម្ពុជា។ ជាងនេះគ្រីស្តបរិស័ទក៏ត្រូវឲ្យចេះគោរពពេលវេលាលោកបូជាចារ្យផងដែរ។ ពិធីតែងតាំងធ្វើឡើង ដោយលោកអភិបាលទ្រាបដៃ រួមជាមួយបូជាចារ្យទាំងអស់ម្តងម្នាក់ៗ ដើម្បីបញ្ជាក់ថា អស់លោករួបរួមជាមួយអភិបាលរបស់ខ្លួន



លោកអភិបាល លោកបូជាចារ្យ ដែលចូលរួមក្នុងពិធីតែងតាំងបូជាចារ្យថ្មី- សម្បត្តិ



លោកបូជាចារ្យថ្មីទទួលប្រេងពីលោកអភិបាល -រូបថត៖ សម្បត្តិ



លោកអភិបាលទ្រាបដៃលើបូជាចារ្យថ្មី-រូបថត៖ សុធីរិទ្ធ

ដើម្បីអង្វរព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីតែងតាំងលោកសុខ ណា ជាបូជាចារ្យ ។ លោកបូជាចារ្យថ្មី សុខ ណា ទទួលឯកសណ្ឋានជាបូជាចារ្យ និងត្រូវបានលោកអភិបាលលាបប្រេងគ្រីស្មាលើបាតដៃ ដើម្បីឲ្យបូជាចារ្យថ្មីនេះបានវិសុទ្ធ ហើយណែនាំប្រជារាស្ត្ររបស់ព្រះអង្គឲ្យបានវិសុទ្ធ និងដើម្បីថ្វាយសក្ការៈបូជារបស់ព្រះអង្គ ។

លោកសិលា សុខ ណា ដែលបានថ្លែងអំណរគុណដល់អស់លោក និងបងប្អូនដែលតែងតែអធិដ្ឋាន លើកទឹកចិត្ត រហូតដល់មានថ្ងៃនេះ ។ លោកបន្តផ្ដាំផ្ញើដល់យុវជនយុវនារី ដែលមានបំណងស្វែង យល់ពីការត្រាស់ហៅ កុំឲ្យភ័យខ្លាចក្នុងការបើកបេះដូងទទួលស្វាគមន៍ព្រះយេស៊ូយាងចូលមកក្នុងដួងចិត្តរបស់ខ្លួន ។ លោកបន្តថា សូមយុវជនទាំងអស់ក្លាហាន និងឈានជំហានទៅមុខជានិច្ច ព្រោះអនាគតរបស់ខ្លួនដែលកំពុងរង់ចាំគឺព្រះគ្រីស្ត ។ លោកបញ្ជាក់ថា៖ " ខ្ញុំហ៊ានអះអាងថា ពេលណាប្អូនៗយល់ព្រមបើចិត្តឲ្យទូលាយ ទទួលព្រះអង្គ ពេលនោះប្អូនមានសេចក្ដីសុខ និងមានសុភមង្គលនៅក្នុងជីវិត ។ " លោកអភិបាល អូលីវីយេ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភ្នំពេញ បានឲ្យលោកបូជាចារ្យ សិលា សុខណា ឲ្យទៅបម្រើព្រះសហគមន៍មណ្ឌលសកម្មភាពភ្នំពេញខាងត្បូង បន្ទាប់ពីការតែងតាំងនេះទៅ ។

ព្រះសហគមន៍កាតូលិកនៅកម្ពុជាមានកំណើតជាង ៤៥០ ឆ្នាំមកហើយ ។ តែដោយសារសង្គ្រាម ក្នុងស្រុកព្រះសហគមន៍មួយនេះបានរសាត់អណ្ដែតតាមគន្លងនៃប្រវត្តិរបស់ប្រជាជនក្នុងប្រទេសមួយនេះ ។ព្រះសហគមន៍ត្រូវបានបំផ្លាញខ្ទេចអស់ក្នុងពេលសង្គ្រាមស៊ីវិល លោកអភិបាល បូជាចារ្យ បព្វជិត បព្វជិតា ជាតិកម្ពុជាត្រូវបានសម្លាប់ និងស្លាប់គ្មានសល់ ។ ព្រះសហគមន៍រស់ឡើងវិញក្នុងទសវត្សឆ្នាំ ១៩៩០ រហូតដល់ពេលនេះមានគ្រីស្តបរិស័ទប្រមាណ ២០០០០ នាក់ និងបូជាចារ្យជាតិកម្ពុជា ចំនួន ៨នាក់ ក្នុងចំណោមជាង ៧០នាក់ ដែលជាជនបរទេស ៕

ដាលីស

# Fr. Peter Sok Na, 8th Local Priest in Cambodia

On the 27th June 2015, Deacon Peter Sok Na was ordained priest in the Apostolic Vicariate of Phnom Penh. The ordination ceremony was officiated by Rt. Rev. Olivier Schmitthaeusleur, the bishop of the Apostolic Vicariate of Phnom Penh. Present at this celebration were the two Apostolic Prefects, Msgr. Enrique Figaredo of Battambong and Msgr. Antonysamy of Kampong Cham Prefectures. The ordination service took place at St. Joseph's Church located in Phsar Touch, Phnom Penh. The ceremony began with a solemn procession as the congregation sang the entrance hymn with great joy while deacon Sok Na went up to the altar. It was a joyful occasion for the Catholic Church in Cambodia, especially the Apostolic Vicariate of Phnom Penh. Also present at the service were more than 50 priests and an estimated 2,000 people.

When the procession arrived at the stage, Fr.Un Son, the Master of ceremonies called Deacon Peter Sok Na to make his appearance in front of all present. Fr. Robert Piché (Bob), the rector of the Major Seminary, assured Bishop Olivier that Deacon Peter Sok Na is really qualified to be ordained a priest.

Fr. Mario Ghezzi, the Vicar General, (VG) in his introduction made mention of the qualities of Deacon Peter Sok Na whom he had known since 2001 by saying that the candidate has always focused his attention on friendship with Jesus in prayer, discerning the presence of Jesus in life, being considerate to the poor by knowing that the people embody Jesus, in His suffering. Deacon Sok Na also handled liturgical rites (Mass) and trained altar servers. He has also shown interest for those who seek to be called to serve as priests, religious who have the intention of serving as missionaries in order to proclaim the Good News of God to other people. To respond to such an assurance, the bishop made an announcement about choosing Deacon Sokna to be ordained priest with the support of Jesus. In his homily, the bishop said that this was the plan of God and the fruits that have resulted from the prayer and exemplary models of brothers and sisters. The bishop pointed out this was not a word from his mouth but from the Word of God Himself. The bishop continued by saying: "Thanks to the power of the Holy Spirit, by the laying on of hands, Deacon Sok Na will become a priest and friend, whom Jesus has chosen. Like Jesus Fr. Sok Na will offer himself to the people he serves and in this way bring happiness to others. Living a prayerful life and being faithful to his mission as a priest he will bring fullness to his life as a minister of the Church.

The bishop also instructed all the parishioners, especially new priests to enter deeply into the priestly life with four goals. "From today Fr. Sok Na no longer lives a private life; he offers his life publicly for Jesus by honestly serving the Church, educating other people to have faith and to be in communion with Christ and a good shepherd full of love for all human beings."

In his instructions, the bishop further said: "You have to be humble by taking Mary, St. Joseph, John the Baptist and Mother Therese as models of faith in order to make the presence of Jesus and the Providence of God felt by other people. At the same time you have to have a sense of compassion – it is the way Jesus forgives and looks at those who have difficulties in loving Him. Priests have to sacrifice themselves for all people and not only a handful of persons whom he knows."

The bishop also delivered a message to all the Catholics, especially youths to be awake answering the call to have more priests and religious in Cambodia. At the very beginning, Deacon Sok Na prostrated at the foot of the altar as the sign of humility and submission to God while the bishops, priests and the congregation sang the Litany of saints. The ordination rite was carried out by laying on of hands on the candidate by the priests present in order to confirm that priests along with their bishop were asking the Holy Spirit's outpouring of Grace for Sok Na to be ordained.

The highlight of the ordination ceremony was the promise of obedience by the candidate to the bishop followed by the anointing of the candidate's hands with Chrism by the ordaining bishop as he said the consecrating prayer so that the new priest becomes holy to lead His people to holiness and make offerings to Him. Following this, the vesting took place with the placing of the stole across his shoulder over which the red chasuble was placed. The bishop then introduced the newly ordained priest, Fr. Peter Sok Na to the congregation at which those present gave a thunderous applause. At the end of rite of ordination, Fr. Peter Sok Na thanked the priests and all present for their prayers and encouragement. The new priest also delivered a message to the youths who intended to learn to understand the calling by saying 'Don't be afraid' of opening wide your hearts in welcoming Jesus, who wants to come into their hearts. The priest further said: "May all the youth be courageous and go a step further always because their future is with Christ." The priest said: "I assure you that when you agree to open wide your hearts to receiving Him, then you will have peace and happiness in life."

After the ordination service, Bishop Olivier in his capacity as the bishop of the Fr. Peter Sok Na announced that he will be assigned to the pastoral sector of Southern Phnom Penh. It should be pointed out here that the Catholic Church in Cambodia was established over 450 years ago. Unfortunately the civil war of the 1970s scattered and destroyed the church throughout the country. During this period the bishops and priests were tortured and killed. After much sufferings and uncertainty, the Catholic Church came to life in the 1990s. Today there are an estimated 20,000 Catholics with 8 local and 70 foreign priests serving the pastoral needs of the Catholic community in Cambodia.

# ជីវប្រវត្តិសង្ខេបរបស់ លោកបូជាចារ្យសិលា សុខ ណា

Biography of Fr. Peter Sok Na



លោកបូជាចារ្យ សិលា សុខ ណា កើតថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៩ នៅភូមិលូ ឃុំព្រែកព្នៅ ស្រុកពញាឮ ខេត្តកណ្តាល (ស្វាយប៉ាក)។លោកត្រូវជាកូនរបស់លោកសុខ សាង ជាកម្មករនេសាទ និងអ្នកស្រី លឹម ស្រីឡាង ជាអ្នកលក់ដូរតិចតួចនៅផ្ទះ និងជាក្រុមគ្រួសារគ្រីស្តបរិស័ទ ដែលមានបងប្អូន៥នាក់ ក្នុងនោះស្រី៤នាក់ហើយ លោក សុខ ណា ជាកូនពៅក្នុងក្រុមគ្រួសារ ។

កាលនៅជាកុមារ ជាក្មេងស្លូត ចូលចិត្តរៀនសូត្រ និងទទួលការអប់រំជំនឿតាមរយៈក្រុមគ្រួសារនិងចេះសូត្រធម៌រត់មាត់យ៉ាងស្ទាត់ជំនាញ ជារបៀបអធិដ្ឋានតាមទំលាប់របស់ក្រុមគ្រួសារ។ ហើយតែងតែតាមឪពុកម្តាយទៅចូលរួមអធិដ្ឋានជាមួយគ្រីស្តបរិស័ទផ្សេងទៀតក្នុងភូមិ និងចូលរួមអភិបូជាថ្ងៃអាទិត្យ។ យូរៗម្តង កុមារ សុខ ណាទៅព្រះវិហារសន្តយ៉ូសែបផ្សារតូច ព្រោះពិបាកក្នុងការធ្វើដំណើរ រីឯក្រុមគ្រួសារក៏គ្មានមធ្យោបាយធ្វើដំណើរដែរ ។

ដោយមានបញ្ហាជីវភាព ក្រុមគ្រួសារមិនសូវជាធូធារ លោកសុខ ណា ចូលរៀនចំណេះដឹងទូទៅយឺត ហើយរៀនមិនទាន់បានចប់បឋមសិក្សាផង ក៏ត្រូវឈប់រៀនវិញដើម្បីរករៀនជំនាញឲ្យឆាប់មានការងារធ្វើ។

ដូច្នេះលោកបានរៀនកាត់ដេរនិងធ្វើជាងកាត់ដេរអស់រយៈពេល៧ឆ្នាំ។ ក្រោយមក លោកត្រូវសម្រេចចិត្តចូលទេវវិទ្យាល័យនៅឆ្នាំ២០០១។

ពេលនោះលោកជួបឧបសគ្គយ៉ាងច្រើនមានជាអាទិ៍ រយៈពេលដែលលោកឈប់រៀនយូរពេក ម្យ៉ាងវិញទៀតលោកជាស្នូលនៃក្រុមគ្រួសារ ពីព្រោះបងស្រីទាំងបីមានគ្រួសាររៀងៗខ្លួន និងម្នាក់ទៀតពិការ ហើយលោកកំពុងមានសង្សារដែលស្រឡាញ់គ្នារយៈពេល៣ឆ្នាំ ជាពិសេសនោះលោកកំពុងមានបញ្ហាសុខភាពផងដែរ។

នៅឆ្នាំដដែលនោះ លោកបូជាចារ្យ អូមែរ ជានាយក និងលោកឪពុកប្រ៊ុយណូជានាយករង បានទទួលលោក និងបានផ្ញើលោក សុខ ណា ទៅបន្តរៀននៅមណ្ឌលដើម្បីភាពញញឹមនៃកុមាររយៈពេល៦ឆ្នាំដើម្បីបញ្ចប់កំរិតមធ្យមទុតិយភូមិ។

ក្រោយមកលោកបានបន្តរៀន ទស្សនវិជ្ជានៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ អស់រយៈពេល៤ឆ្នាំ ហើយបន្ទាប់ពីនោះបានបន្តរៀនថ្នាក់ទេវវិទ្យានៅទេវវិទ្យាល័យរយៈ៣ឆ្នាំ។

នាថ្ងៃ១៨មិថុនា ២០១៤ ព្រះសហគមន៍កាតូលិក បានតែងតាំងលោកជាឧបដ្ឋាក និងបានទទួលអគ្គសញ្ញាបូជាចារ្យ នៅថ្ងៃ២៧ មិថុនា ២០១៥នេះ៕ ដាលីស

Fr. Peter Sok Na was born on June 25, 1979 in a Catholic family at Lou village, Prek Phnov commune, Ponhea Leur district, Kandal province (svay Pak). He is the son of Mr. Sok Sang, a fisherman and Mrs. Lim Sreylang, a grocery vendor. Fr. Sok Na is the youngest son in his family and has four sisters.

As a child, he was a docile person and liked to study and received his faith formation through his family and so he knew how to recite prayers fluently. He always followed his parents to attend the prayer service with other parishioners in the village including attending Sunday Masses. Occasionally he went to St. Joseph's church in Phsar Touch although it was far and transportation was not easily available.

Faced with financial difficulties, the family was not well-off. Sok Na attended the school of general knowledge late in his teenager and could not complete elementary education. He stopped studying and wanted to work. Therefore he learnt sewing skills and worked as a tailor for a period of 7 years. Then in 2001 he decided to attend the Major Seminary where he continued his academic studies and the seminary internship.

At that time he faced many difficulties as his family was going through a hard time since his three older sisters got married with one sister becoming disabled. Furthermore, he himself had some health problems.

That same year, Fr. Omer, the rector of the Major Seminary and Fr. Bruno Cosme, the vice rector sent him to continue his studies at Pour un Sourie d'Enfant (PSE) (for a child of Smile) for six years. Here he completed his secondary education. Later he continued his studies in philosophy for four years at the Royal University of Phnom Penh. Having completed this he did his theological studies at the Seminary for three years.

On 18th June 2014, after having completed his seminary studies Sok Na was ordained a deacon. On 27th of June 2015, in the presence of a large crowd of priests and the faithful deacon Sok Na was ordained a priest by Rt. Rev Olivier Schmitthasleur, the bishop of the Apostolic Vicariate of Phnom Penh.

# អធិដ្ឋានពេញមួយយប់សំរាប់ការត្រាស់ហៅលើកទី៣៩




មណ្ឌលសកម្មភាពខេត្តព្រះសីហនុ បានរៀបចំកម្មវិធីអធិដ្ឋានពេញមួយយប់ សម្រាប់ការត្រាស់ហៅលើកទី៣៩ នៅព្រះសហគមន៍ សន្តមីការអែលក្រុងព្រះសីហនុ ដោយមានវត្តមានលោកអភិបាល និងលោកបូជាចារ្យទាំងបីភូមិភាគ និងគ្រីស្តបរិស័ទសរុបប្រមាណជា១៧០នាក់នៅល្ងាចថ្ងៃទី៤មិថុនា២០១៥។

លោកឧបដ្ឋាក សុខ ណា បានណែនាំគ្រីស្តបរិស័ទទាំងអស់នៅក្នុងឱកាសនេះ ឲ្យយល់ពីជីវិតជាគ្រីស្តបរិស័ទឲ្យស្គាល់ពីវិន័យរបស់ព្រះជាម្ចាស់និងឲ្យមានចិត្តស្រលាញ់យ៉ាងពិតប្រាកដ ថែមទាំងឲ្យយល់ពីតម្លៃនៃការជឿលើព្រះជាម្ចាស់ គឺមិនមែនជាការអួតបំប៉ោងនោះទេ តែត្រូវដាក់ចិត្តសុភាពរាបសា ដោយយកគំរូតាមព្រះយេស៊ូ។


ពិធីអធិដ្ឋានពេញមួយយប់នៅកំពង់សោម-រូបថត៖ លី សុវណ្ណា

យុវជន ឧសភា ដែលបានចូលរួមក្នុងកម្មវិធីអធិដ្ឋាននេះបានឲ្យដឹងថា"នេះគឺជាឱកាសដ៏មានតម្លៃសម្រាប់ខ្ញុំ ដែលត្រូវទូលអង្វរព្រះជាម្ចាស់ ដើម្បីបំភ្លឺគោលដៅនៃជីវិតនិងទទួលអគ្គសញ្ញាលើកលែងទោសដើម្បីចូលកាន់តែជិតស្និទ្ធជាមួយព្រះអង្គ។"

ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានរៀបចំការអធិដ្ឋានពេញមួយយប់ជាទៀងទាត់និងរៀងរាល់ខែ នៅតាមមណ្ឌលសកម្មភាពនីមួយៗក្នុងភូមិភាគនេះ៕

តូច ពឿន

## 39th All-Night Prayer vigil For Vocations

On the evening of 4th June 2015 the Preah Sihanouk ville province pastoral sector organized an all-night prayer for vocations for the 39th time at St. Michael Parish. About 170 persons including the bishops, priests and parishioners from the three dioceses participated in the vigil.

Deacon Peter Sok Na instructed all the Catholics during the occasion to understand about Catholics' lives, to know about the commandments of God and to have a true heart of love as well as to understand values and faith in God, He urged all to be humble by following the example of Jesus.

A youth Ou Saphea, one of the participants said: "This is a precious occasion for me to petition God to be enlightened in the goal of life and to be faithful to the Sacrament of Penance in order to come close to Him."

The Apostolic Vicariate of Phnom Penh organizes such all night prayer vigils regularly every month in each sector of the diocese.

# ព្រះសហគមន៍ជុំគីរី បង្ហាញមេត្តាករុណាដល់អ្នកភូមិ

## Church builds house for Villagers

ព្រះសហគមន៍ជុំគីរី នៃមណ្ឌលសកម្មភាពកំពត បានទិញដី និងសាងសង់ផ្ទះ ដែលមានបណ្ដោយ ៥ម៉ែត្រ និងទទឹង៤ម៉ែត្រ ឲ្យអ្នកដែលទីទ័លក្រខ្លាំងក្នុងភូមិ កាលពីកាលពីពាក់កណ្ដាលខែមិថុនានេះ ដោយមានការជួយជ្រោមជ្រែងផ្នែកកម្លាំង ពីក្រុមយុវជននៃព្រះសហគមន៍នេះផងដែរ។

លោកបូជាចារ្យ តាវ៉ូឡា យ៉ាំងលូកា ជាអ្នកទទួលខុសត្រូវព្រះសហគមន៍នេះ ក៏ដូចជាមណ្ឌលសកម្មភាពកំពតទាំងមូល បានឲ្យដឹងថា៖ ព្រះសហគមន៍មានបំណងសម្ដែងធម៌មេត្តាករុណា ដល់បងប្អូនឯទៀត ដោយត្រូវជួយគ្នាទៅវិញទៅមក ដូចបងប្អូនបង្កើត ដើម្បីបង្ហាញពីសេចក្ដីស្រឡាញ់របស់ព្រះយេស៊ូចំពោះយើងទាំងអស់គ្នា និងក៏ជារបៀបប្រកាសដំណឹងល្អដល់អ្នកក្រីក្រ។

លោកបន្ថែមថា៖ព្រះសហគមន៍តែងតែយកចិត្តទុកដាក់ជួយដល់អ្នកជម្ងឺ យុវជន ដែលពុំមានលទ្ធភាពសិក្សា និងអ្នកក្រីក្រដែលដាច់ពេល។ ជាក់ស្ដែង ព្រះសហគមន៍ បានជួយទិញដី និងសង់ផ្ទះមួយខ្នងដល់លោកទូច និងអ្នកស្រីយិន ដែលជាគ្រួសារក្រីក្រទីទ័លខ្លាំងបំផុត។ ហើយសកម្មភាពទាំងនេះយើងធ្វើទៅបានអាស្រ័យទៅលើតំរូវការពិសេសដែលបានជួប គឺមានន័យថាព្រះសហគមន៍ព្យាយាមធ្វើតាមអ្វីដែលជាតំរូវការចាំបាច់របស់បងប្អូនទាំងនោះ។

លោកបូជាចារ្យបានបង្ហើបឲ្យដឹងទៀតថា៖ ព្រះសហគមន៍ មានគំរោងជួយសាងសង់ផ្ទះដល់អ្នកក្រីក្រទីទ័លខ្លាំងចំនួន៣ផ្ទះបន្ថែមទៀត នាពេលខាងមុខឆាប់ៗនេះ ដោយអាស្រ័យទៅលើថវិកា និងកម្លាំង ដើម្បីឲ្យពួកគេមានផ្ទះនៅសមរម្យ៕ ដាលីស

St. Joseph Church in Chumkiri in the pastoral sector of Kampot bought a plot of land in mid-June of 2015 and built a house measuring 5 meters by 4 meters on this land for a very poor family. The youth of the church cooperated by providing the manpower.

Fr. Gianluca Tavola, the priest in charge of the parish including the pastoral sector of the whole Kampot said: "The parish has a need to show kindness for other people by helping one another. This is a way to express the love of Jesus for all of us and the way of proclaiming the Good News to the poor."

The priest further said the parish always focuses her attention to helping the poor, the sick, the youth who are unable to go to school and the hungry. Hence, the parish, has helped by buying the plot of land to built a house for Mr. Touch and Mrs. Yin who are very poor. "The work we have done is based on the special needs seen, which means that the parish tries to do something that is a felt need by the people."

The priest gave the hint that the parish was planning to help with the construction of three more houses for the poor in the near future within the budget available and its capacity so that the poor and needy have proper houses.

In the past Chumkiri Church have initiated activities visiting the poor, elderly, making of referral of patients to hospitals, the provision of scholarship grants to poor student and so on.



ក្រុមគ្រួសារក្រីក្រដែលទទួលបានផ្ទះ និងដីពីព្រះសហគមន៍ជុំគីរី -រូបថត៖ DR

# យុវជនអំពៅព្រៃរៃអង្គាសថវិកាជួយអ្នកក្រខ្សត់

## Youth Solicit Contributions for the Needy



គ្រីស្តបរិស័ទកំពុងអធិដ្ឋាននៅព្រះសហគមន៍អំពៅព្រៃ-រូបថត៖ សំនៀង

យុវជននៃព្រះសហគមន៍អំពៅព្រៃនៃមណ្ឌលសកម្មភាពតាខ្មៅបានចុះសួរសុខទុក្ខគ្រួសារក្រីក្រ និងអ្នកជម្ងឺចំនួន៣២គ្រួសារ ស្ថិតក្នុងភូមិតាដោល ឃុំអំពៅព្រៃ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៥ កន្លងមកនេះ។

យុវនារីផល្លា សុខចាន់ ដែលជាមេក្រុមយុវជនបានឲ្យដឹងថា៖ ការចុះមកសួរសុខទុក្ខនេះ និងជូនទាននេះ គឺមានគោលបំណងចង់លើកទឹកចិត្តនិងបង្ហាញសេចក្តីស្រលាញ់ដល់ជនចាស់ជរា និងអ្នកជំងឺ។

សុខចាន់បន្តថា ក្រុមយុវជនក៏ចង់ បង្ហាញឲ្យយុវជនយុវនារីដែលរស់នៅជុំវិញព្រះសហគមន៍យល់ពីការស្រលាញ់មេត្តាករុណាដែលយើងត្រូវធ្វើចំពោះអ្នកក្រខ្សត់ផងដែរ។

សុខចាន់បានឲ្យដឹងទៀតថា សម្ភារនិងគ្រឿងឧបភោគបរិភោគទាំងនេះ គឺយើងបានចែកជូនដល់គ្រួសារចាស់ជរា ២គ្រួសារ និងគ្រួសារអ្នកជំងឺ១គ្រួសារ ដែលថវិកាទាំងនេះបានមកពីការរៃអង្គាសពីក្រុមយុវជននៃព្រះសហគមន៍ដោយផ្ទាល់៕

សំនៀង

The youth of Ompov Prey parish in the pastoral sector of Takmao solicited funds to help needy families in Tadaul Village, Ompov Prey Commune, Kandal Steung district in Kandal province. Last June 1st, they visited 32 families of the poor and sick in the area.

Phalla Sokchan, the head of the youth said: "These visitations and offerings are intended to show love for the elderly and sick, and encourage more youth living around the parish to share love, kindness and what we have with the poor. From the money collected, mostly from the youth of the parish themselves, we were able to distribute basic commodities. Among the recipients were two elderly families and one where the members were mostly sick."

# ក្រុមមេត្តាករុណាយកចិត្តទុកដាក់អំពីគ្រួសារក្រីក្រ

ក្រុមមេត្តាករុណានៃព្រះសហគមន៍ព្រះត្រៃឯកគិរីវង់ ដែលស្ថិតនៅក្នុងភូមិព្រៃជើង ឃុំគោកព្រេច ស្រុកគិរីវង់ ខេត្តតាកែវ ដែលមានសមាជិក៥នាក់ បានចុះទៅសួរសុខទុក្ខ និងនាំយកនូវគ្រឿងឧបភោគបរិភោគដល់គ្រួសារ ដែលមានវ័យចាស់ជរានិងមានជីវភាពខ្វះខាតកាលពីថ្ងៃអាទិត្យទី០៧ ខែមិថុនា ឆ្នាំ២០១៥កន្លងទៅនេះ។

តាមសម្ដីរបស់លោកតា សុខ ដែលជាប្រធានក្រុមមេត្តាករុណាបានឲ្យដឹងថា៖ ជារៀងរាល់ខែក្រុមនេះមានគោលដៅធ្វើសកម្មភាពនេះ ដល់គ្រួសារចំនួនពីរគ្រួសារ។

លោកតាសុខ ឲ្យដឹងទៀតថាក្នុង១ខែម្ដង ក្រុមមេត្តាករុណានេះមានសកម្មភាពជួយដល់អ្នកក្រីក្រចាស់ជរានិងអ្នកជំងឺ ដោយផ្ដល់ជាម្ហូបអាហារ គ្រឿងឧបភោគបរិភោគ និងបញ្ជូនអ្នកជំងឺទៅកាន់មន្ទីរពេទ្យជាដើម។

នៅក្នុងខែនេះក្រុមមេត្តាករុណាបានសួរសុខទុក្ខដល់គ្រួសារលោកតាឃិនដែលមានអាយុ៨១ឆ្នាំ និងគ្រួសារលោកយាយពៅ ដែលមានអាយុ៨៦ឆ្នាំ ដែលកំពុងមានជីវភាពខ្វះខាតជាខ្លាំង និងមានភាពចាស់ជរាមិនអាចធ្វើការងារអ្វីបាន។ លោកយាយគាត់ខ្វិន ដោយសារគាត់ត្រូវបានស្វិតជើងទាំងសងខាង ហើយគាត់បានរស់នៅជាមួយ និងកូនស្រីរបស់គាត់ដែលនៅលីវមានអាយុ៥០ឆ្នាំ និងមានជំងឺទៀត។

ជាមួយគ្នានេះដែរ លោកយាយពៅដែលមានអាយុ៨៦ឆ្នាំស្វិតជើងទាំងសងខាង កំពុងរស់នៅជាមួយកូនស្រីរបស់គាត់បានមានប្រសាសន៍ថា៖"ខ្ញុំមានអំណរសប្បាយនិងរំភើបជាខ្លាំងរកអ្វីមកប្រៀបផ្ទឹមពុំបាននោះទេ ព្រោះខ្ញុំកំពុងតែខ្វះខាត។ បានមីមួយកេះ ទឹកត្រី ទឹកស៊ីអ៊ីវ ប្រេងឆា ទឹកត្រចៀកកាំមួយយួរ អាចជួយដោះស្រាយជីវភាពខ្ញុំបានមួយរយៈពេលដែរ"៕ សុខណាន



គ្រីស្តបរិស័ទគីរីវង់ចុះជូនអំណោយដល់គ្រួសារក្រីក្រ-រូបថត៖ DR

## Charity Group Mindful of Poor Families

Five members of the Charity group of the Holy Trinity Church located in Prey Choeung village, Kokprich commune, Kirivong district; Takeo province last 7th June 2015 visited and brought some essential commodities for the impoverished families with the elderly.

Grandfather Sok the head of the Charity group said that every month the group has set a goal of carrying out the activities for two families. Once a month the group has initiated activities for the poor, elderly and sick by distributing food rations, essential necessities and the referral of patients to a hospital.

In this month the Charity group visited the families of 81-year-old grandfather Yen and 86-year-old grandmother Pov, who are living in extreme shortage and too old to work. She was a lame because both of limps have withered and she lives with her 50-year-old unmarried daughter inflicted with a disease.

The 86-year-old grandmother said: “I feel happy and excited incomparably because I am experiencing shortage I was offered a box of noodle, fish sauce, soy sauce, cooking oil and sparrow juice which could help handle my livelihood for some time.”

# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# ក្នុងឱកាសបុណ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងមក
# នៅព្រះវិហារសន្ត:យ៉ូសែប ផ្សារតូច ថ្ងៃទី ២៤ ឧសភា ២០១៥

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងទទួលព្រះវិញ្ញាណដ៏វិសុទ្ធដែលយាងមកសណ្ឋិតលើយើង។ ព្រះយេស៊ូប្រទានព្រះវិញ្ញាណឲ្យយើងទុកជាព្រះអំណោយទានដ៏វិសេស។ ក្នុងឱកាសនេះ យើងគិតម្តងទៀតពីជីវិតរបស់យើងជាគ្រីស្តបរិស័ទ ដែលត្រូវរស់នៅឲ្យស្របតាមព្រះបន្ទូល ដូចដែលយើងបានស្តាប់អំបាញ់មិុញ គឺឲ្យយើងមានសេចក្តីស្រឡាញ់ អំណរ សេចក្តីសុខសាន្ត ចិត្តអត់ធ្មត់ ចិត្តសប្បុរស ចិត្តសន្តោសមេត្តា ជំនឿ ចិត្តស្លូតបូត និងចេះទប់ចិត្តខ្លួនឯង។ ជាការពិតណាស់ ថ្ងៃនេះយើងរួមជាមួយគ្នាទទួលព្រះអំណោយទានយ៉ាងពិសេសនេះពីព្រះយេស៊ូផ្ទាល់ គឺទទួលព្រះវិញ្ញាណដ៏វិសុទ្ធដែលផ្តល់កម្លាំងថ្មីឲ្យយើង និងណែនាំយើងឲ្យស្គាល់សេចក្តីពិតដ៏ពេញលក្ខណៈ។

ថ្ងៃនេះ គឺជាឱកាសមួយសម្រាប់បងប្អូនដែលទទួលអគ្គសញ្ញាលាបថ្វាស ដើម្បីគិតអំពីជីវិតផ្ទាល់ខ្លួនជាគ្រីស្តបរិស័ទ ហើយក៏រួមគិតពិចារណាជាមួយយើងទាំងអស់គ្នា ដែលនៅទីនេះ ថាតើយើងធ្វើដូចម្តេចដើម្បីទៅជាគ្រីស្តបរិស័ទស្របតាមព្រះបន្ទូលរបស់ព្រះយេស៊ូ ជាពិសេសគឺស្របតាមព្រះវិញ្ញាណដ៏វិសុទ្ធ ដែលណែនាំជីវិតយើងគ្រប់ពេលវេលា៖ ទីមួយ គឺជួបនិងជួបទៀតជាមួយព្រះយេស៊ូផ្ទាល់។ ថ្ងៃនេះជាឱកាសមួយ ដែលបងប្អូនទទួលអគ្គសញ្ញាលាបថ្វាស នឹងទទួលសេចក្តីពិតដើម្បីដឹងច្បាស់ថាព្រះយេស៊ូជានរណា? បងប្អូនបានទទួលការអប់រំជំនឿយូរខែឆ្នាំមកហើយ បងប្អូនបានទទួលចំណេះដឹងជាច្រើន ប៉ុន្តែថ្ងៃនេះ តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ បងប្អូនមិនត្រឹមតែទទួលចំណេះដឹងបន្ថែមប៉ុណ្ណោះទេ ប៉ុន្តែបងប្អូននឹងទទួលព្រះអំណោយទានយ៉ាងពិសេសថែមទៀត គឺជីវិតរបស់បងប្អូនផ្ទាល់ នឹងភ្ជាប់ជាមួយព្រះយេស៊ូទៅជាធ្លុងតែមួយជាមួយព្រះអង្គ ទៅជាគ្រីស្តបរិស័ទដ៏ពិតប្រាកដ ដែលមានព្រះយេស៊ូផ្ទាល់នៅក្នុងជីវិតរបស់បងប្អូន។

តាមពិតយើងទាំងអស់គ្នាមិនជួបព្រះយេស៊ូតែម្តងប៉ុណ្ណោះទេ ក៏ប៉ុន្តែយើងត្រូវការជួបព្រះអង្គជារៀងរាល់ថ្ងៃៗ គឺជួបម្តងហើយម្តងទៀត និងយើងត្រូវរស់នៅតាមព្រះបន្ទូល ដើម្បីទៅជាសញ្ញាសម្គាល់របស់ព្រះយេស៊ូ និងទៅជាគ្រីស្តបរិស័ទដែលរួមជាធ្លុងតែមួយជាមួយព្រះយេស៊ូ។ ទីពីរ ឲ្យយើងមានមានចិត្តស្រឡាញ់ និងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការប្រកាសអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ អម្បាញ់មិុញយើងបានស្តាប់ឮព្រះបន្ទូល ដែលសូមឲ្យយើងរស់នៅក្នុងព្រះអំណោយទាន ដែលជាសញ្ញាសម្គាល់ថាយើងបានរស់នៅក្នុងរបៀបព្រះយេស៊ូពិតមែន។ ប៉ុន្តែត្រូវដឹងថា យើងមិនទទួលព្រះអំណោយទានទុកសម្រាប់តែខ្លួនឯងប៉ុណ្ណោះទេ គឺយើងមានបេសកម្មយ៉ាងពិសេស ប្រកាសដំណឹងល្អឲ្យមនុស្សជាច្រើនទៀតបានទទួលព្រះអំណោយទាននេះ នៅក្នុងជីវិតរបស់គេដែរ។

តើយើងត្រូវប្រកាសដំណឹងល្អអ្វី? អម្បាញ់មិុញយើងស្តាប់ឮថា ពេលក្រុមគ្រីស្តទូតបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធហើយ នោះពួកគេចេញទៅប្រកាសអំពីការអស្ចារ្យរបស់ព្រះជាម្ចាស់ គឺប្រកាសអំពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ សេចក្តីដែលក្រុមគ្រីស្តទូតប្រកាសនោះ គឺជាដំណឹងល្អដែលយើងប្រកាសនៅពេលសព្វថ្ងៃនេះ ប៉ុន្តែយើងប្រកាសតាមជីវិតរបស់យើង។ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញមានន័យថាព្រះយេស៊ូបានឈ្នះសេចក្តីស្លាប់សេចក្តីស្លាប់ភាពងងឹតមិនមានអំណាចលើជីវិតទៀតទេ ដូច្នេះយើងរស់នៅជាប្រជារាស្ត្រនៃសេចក្តីសង្ឃឹម។ ហេតុនេះហើយ អ្វីៗទាំងអស់ដែលកើតមាននៅលើផែនដីនេះ ដូចជាសង្គ្រាម គ្រោះធម្មជាតិ ភាពក្រីក្រ ជម្លោះទាស់ទែងក្នុងគ្រួសារ...។ល។ ឬទោះបីជីវិតរបស់យើងកំពុងជួបនឹងទុក្ខវេទនា ជួបបញ្ហានានាយ៉ាងណាក្តី ក៏យើងដឹងថាយើងបានរួមជាមួយព្រះយេស៊ូ ដែលរងទុក្ខលំបាក និងយើងក៏រួមជាមួយព្រះអង្គ ដែលរស់ឡើងវិញប្រកបដោយសិរីរុងរឿងដែរ។ នេះជាន័យនៃព្រះយេស៊ូមានព្រះ

ជន្មរស់ឡើងវិញ សម្រាប់ជីវិតរបស់យើងបច្ចុប្បន្ននេះ។ ដូច្នេះយើងត្រូវគិតថា នៅក្នុងជីវិតខ្ញុំផ្ទាល់ ខ្ញុំពិបាកដូចគេ ខ្ញុំឈឺចិត្តដូចគេ ក៏ប៉ុន្តែខ្ញុំមានព្រះយេស៊ូ គង់នៅជាមួយ ព្រះអង្គជាពន្លឺ ជាសេចក្តីសង្ឃឹមដ៏កំពូល ដែលណែនាំឲ្យខ្ញុំរស់នៅតទៅមុខទៀត។ នេះជាសេចក្តីដែលយើងត្រូវចែកទៅបងប្អូនឯទៀតៗ នៅពេលយើងប្រកាសអំពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញដើម្បីឲ្យគេរកឃើញសេចក្តីស្រឡាញ់ថែមទៀតរកឃើញសេចក្តីសង្ឃឹមនៅក្នុងជីវិតរបស់ពួកគេដើម្បីឲ្យទាំងគេនិងទាំងយើងដែរអាចបន្តដំណើរទៅមុខបាន។

ថ្ងៃនេះយើងទទួលអំណោយទានយ៉ាងពិសេសពីព្រះវិញ្ញាណដ៏វិសុទ្ធ គឺឲ្យយើងដែលជាជាតិសាសន៍ ផ្សេងគ្នាបានមកជួបជុំគ្នាទៅជាមហាគ្រួសារតែមួយ ឲ្យយើងរួមរស់ជាធ្លុងតែមួយជាមួយគ្នានិងជាមួយព្រះយេស៊ូ ឲ្យយើងទៅជាសាក្សីនៃជីវិតថ្មី។ បន្តិចទៀតនៅពេលទទួលព្រះកាយព្រះគ្រីស្ត សូមឲ្យយើងនឹកឃើញថា មិនមែនតែខ្ញុំដែលទទួលព្រះកាយព្រះគ្រីស្ត គឺបងប្អូនប្រមាណ ១.៥០០ នាក់អង្គុយនៅទីនេះ ក៏នឹងទទួលព្រះកាយព្រះគ្រីស្តដូចខ្ញុំដែរ ដូច្នេះយើងទាំងអស់គ្នាមានព្រះកាយព្រះគ្រីស្តនៅក្នុងខ្លួនដែលណែនាំឲ្យយើងទៅជាធ្លុងតែមួយទៅជាក្រុមគ្រួសារតែមួយ។ខ្ញុំនៅទីនេះមើលទៅបងប្អូនឃើញពិតមែនថាជាព្រះកាយព្រះគ្រីស្តដែលមានជីវិត ជាព្រះសហគមន៍ដែលរួមគ្នាជាធ្លុងតែមួយ ជាមហាគ្រួសារតែមួយ។ ថ្ងៃនេះយើងបានរួមគ្នាជាបងប្អូន ដូច្នេះយើងត្រូវតែថែរក្សាគ្នា ត្រូវចែករំលែកគ្នា និងត្រូវបន្តអនុវត្តរហូតនៅក្នុងជីវិតផ្ទាល់របស់យើង ដូចដែលយើងបានអធិដ្ឋាននៅពេលចូលថា " សូមព្រះអង្គព្រះមេត្តាប្រោសប្រណីឲ្យពិភពលោកដែលបាក់បែកគ្នា ឲ្យរួបរួមគ្នាជាធ្លុងតែមួយវិញ "។ សព្វថ្ងៃ បញ្ហាធំជាងគេនៅក្នុងសង្គមរបស់យើង នៅក្នុងពិភពលោករបស់យើងគឺការបាក់បែកគ្នា ដោយប្រកាន់ថាយើងជាក្រុមផ្សេងៗពីគ្នា។ ដូច្នេះ ដើម្បីទៅជាធ្លុងតែមួយ នោះយើងត្រូវតែបង្កើតការសន្ទនារវាងគ្នានិងគ្នា។

ប៉ុន្មានថ្ងៃមុន ខ្ញុំបានបង្កើតសិក្ខាសាលានៅវិទ្យាស្ថានសន្ត:ប៉ូល នៅខេត្តតាកែវក្រោមប្រធានបទ " គន្លឹះដ៏មានតម្លៃក្នុងការកសាងសង្គមកម្ពុជានៅសតវត្សទី២១"។ នៅថ្ងៃទី២ នៃសិក្ខាសាលា ខ្ញុំបាននិមន្តព្រះសង្ឃ អញ្ជើញអ៊ីម៉ាំ នៃសាសនាអ៊ីស្លាម និងមានខ្ញុំជាតំណាងសាសនាកាតូលិក ដើម្បីឲ្យតំណាងនៃសាសនានីមួយៗបង្ហាញអំពីរបៀបដែលយើងខិតខំកសាងសង្គមកម្ពុជានៅសតវត្សទី ២១ នេះ។ និស្សិតនៃវិទ្យាស្ថានសន្ត:ប៉ូលខ្លះជាគ្រីស្តបរិស័ទ។ នៅពេលស្តាប់ព្រះសង្ឃ ស្តាប់លោកអ៊ីម៉ាំនៃសាសនាអ៊ីស្លាម និងលោកអភិបាលនៃព្រះសហគមន៍កាតូលិកហើយ នោះនិស្សិតដែលចូលរួមគេភ្ញាក់ស្មារតី ព្រោះជាលើកទីមួយដែលគេបានស្តាប់ទស្សនៈនៃសាសនានីមួយៗយ៉ាងដូច្នេះ។ តាមធម្មតាពុទ្ធបរិស័ទក្តី គ្រីស្តបរិស័ទក្តី អ៊ីស្លាមបរិស័ទក្តីគេមិនដែលរវីរវល់ដើម្បីស្គាល់សាសនាដទៃក្រៅពីសាសនារបស់ខ្លួនឡើយ។ នៅពេលផ្តល់សក្ខីភាព គេបង្ហាញការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយបានស្តាប់ឮសេចក្តីផ្សេងៗពីគ្នានៃសាសនានីមួយៗ។ មានគ្រីស្តបរិស័ទខ្លះបញ្ជាក់ថា " ពេលខ្ញុំស្តាប់ពីទស្សនៈពុទ្ធសាសនា ខ្ញុំគិតថាមានចំណុចល្អ " ។ មានពុទ្ធបរិស័ទខ្លះថា " ពេលខ្ញុំស្តាប់ពីគ្រីស្តសាសនា ខ្ញុំគិតថាមានចំណុចល្អ។ ពីមុនយើងអត់ចេះស្តាប់គ្នា បណ្តាលឲ្យយើងមើលងាយគ្នាទៅវិញទៅមក"។

ដូច្នេះកុំភ្លេចដើម្បីឲ្យយើងទៅជាធ្លុងតែមួយ សុខចិត្តអង្គុយរួមតុតែមួយ យល់ចិត្តគ្នាទៅវិញទៅមករវាងសាសនិកនៃសាសនានីមួយ រវាងជនជាតិនិងជនជាតិ រវាងបងប្អូននិងបងប្អូន រវាងនិស្សិតនិងនិស្សិត រវាងបូជាចារ្យជាមួយបូជាចារ្យ បងស្រីជាមួយបងស្រី បូជាចារ្យជាមួយបងស្រី...នោះយើងត្រូវការការសន្ទនាគ្នា ប្រសិនបើគ្មានការសន្ទនាគ្នាទេ នាំឲ្យយើងយល់ច្រឡំពីគ្នា ហើយការយល់ច្រឡំនេះណែនាំឲ្យយើងបង្កើតរឿងដែលបន្តិចម្តងៗ ទៅជាសង្គ្រាមដ៏ធំដែលគ្មានប្រយោជន៍អ្វីសោះដល់មនុស្សជាតិ។ បើតាមការសង្កេត ពិភពលោកយើងសព្វថ្ងៃមានសង្គ្រាមដោយសារមនុស្សខ្វះការសន្ទនា មិនចង់ស្តាប់គ្នាទៅវិញទៅមក ថាអ្នកនេះមានគំនិតអី? អ្នកនោះមានគំនិតអី?។

ប៉ុន្តែថ្ងៃនេះ យើងជាគ្រីស្តបរិស័ទបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ជាព្រះអំណោយដែលគាំទ្រយើងគ្រប់ពេលវេលា។ ដូច្នេះខ្ញុំសូមអញ្ជើញបងប្អូនទាំងអស់ ឲ្យរួមរស់ជាធ្លុងតែមួយជាមួយព្រះយេស៊ូ ឲ្យប្រកាសជានិច្ចអំពីសេចក្តីសង្ឃឹមដែលមកពីជំនឿ និងឲ្យយកចិត្តទុកដាក់បង្កើតការសន្ទនាគ្នាជានិច្ចផង។ អាម៉ែន!



# វិទ្យាស្ថានសន្តប៉ូល

អាសយដ្ឋាន៖ ភូមិអង្គគីរ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ

Tel: 032 639 0002/ 032 639 0003 | E: spi.takeo@gmail.com | W : www.spi.edu.kh

## ថ្នាក់បរិញ្ញាបត្រ

**មហាវិទ្យាល័យព័ត៌មានវិទ្យា**
**Faculty of Information Technology**

- វិស្វកម្មកម្មវិធី Software Engineering
- ទូរគមនាគមន៍ និងបណ្តាញ **Telecommunication and Network**

**ដេប៉ាតឺម៉ង់អក្សរសាស្ត្រអង់គ្លេស**
**Department of English Literature**

- អប់រំភាសាអង់គ្លេស **Teaching English as Foreign Language**
- ភាសាអង់គ្លេសសម្រាប់ទំនាក់ទំនង **English for Communication**

**ដេប៉ាតឺម៉ង់គ្រប់គ្រងទេសចរណ៍**
**Department of Tourism Management**

- គ្រប់គ្រងទេសចរណ៍ **Tourism Management**

**ដេប៉ាតឺម៉ង់ក្សេត្រសាស្ត្រ**
**Department of Agronomy**

- ក្សេត្រសាស្ត្រ **Agronomy**

**ដេប៉ាតឺម៉ង់សង្គមកិច្ច**
**Department of Social Work**

- សង្គមកិច្ច **Social Work**

## ថ្នាក់បរិញ្ញាបត្ររងជំនាញបច្ចេកទេស

- **អភិវឌ្ឍន៍កម្មវិធីកុំព្យូទ័រ** — **Software Development**
- **គ្រប់គ្រងប្រព័ន្ធ និងបណ្តាញកុំព្យូទ័រ** — **System and Network Administration**
- **បង្រៀនភាសាអង់គ្លេសជាភាសាទីពីរ** — **Teaching English as a Second Language**
- **សណ្ឋាគារ និងបដិសណ្ឋារកិច្ច** — **Hotel and Hospitality**
- **ផលិតកម្មដំណាំឈើហូបផ្លែ និងបន្លែ** — **Fruit and Vegetable Crop Production**
- **ជំនាញកែច្នៃអាហារ** — **Food Processing**
- **ប្រព័ន្ធកសិកម្មចម្រុះ** — **Integrated Farming System**
- **ថែទាំកុមារ** — **Child care**
- **ពេទ្យសត្វ** — **Veterinary**

○ សម្គាល់៖ រៀនបន្ថែម២ឆ្នាំនឹងទទួលបានសញ្ញាបត្របរិញ្ញាបត្រ

## លក្ខខណ្ឌចូលរៀន

១. បេក្ខជនត្រូវមានសញ្ញាបត្រទុតិយភូមិ (ជាប់ថ្នាក់ទី១២) ឬសញ្ញាបត្រដែលមានតម្លៃស្មើ សម្រាប់ចូលរៀនថ្នាក់បរិញ្ញាបត្រ

២ បេក្ខជនធ្លាក់ថ្នាក់ទី១២អាចចូលរៀនថ្នាក់បរិញ្ញាបត្ររងជំនាញបច្ចេកទេស




**ចាប់ផ្តើមលក់ពាក្យ និងទទួលពាក្យ**

*ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ*

- ចូលរៀនវគ្គបំប៉ន ខែកញ្ញា ឆ្នាំ២០១៥
- ចូលរៀនឆមាសទី១ ខែវិច្ឆិកា ឆ្នាំ២០១៥

# សកម្មភាពលោក សុខកុមារ អូលីវីយេ ជ្មីតអឺស្លែរ អភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ ក្នុង ខែកក្កដា ឆ្នាំ២០១៥

## The Activities of Bishop Olivier SCHMITTHAEUSLER, MEP Apostolic Vicar of Phnom Penh in July 2015

១ កក្កដា ៖ ប្រជុំប្រធានក្រុមបព្វជិតបព្វជីតាវៀតណាមដែលធ្វើការនៅភូមិភាគភ្នំពេញ

២ កក្កដា ៖ ប្រជុំក្រុមប្រឹក្សានៅភ្នំពេញថ្មី

៦.៣០ល្ងាចអធិដ្ឋានពេញមួយយប់លើកទី៤០សម្រាប់ការត្រាស់ហៅនៅព្រះសហគមន៍គីរីវង្ស

៣ កក្កដា ៖ ប្រជុំក្រុមសាសនទូតបារាំង MEP

៤ កក្កដា ៖ ប្រជុំប្រចាំខែនៅព្រះសហគមន៍ចំប៉ា

៥ កក្កដា ៖ អគ្គសញ្ញាលាបថ្វាសនៅព្រះសហគមន៍ពោធិ៍ចិនតុង

៦ កក្កដា ៖ ដំណើរទស្សនៈកិច្ចរបស់ក្រុមបេសសកម្មអូស្ត្រាលី

៧ កក្កដា ៖ អភិបូជាបិទឆ្នាំសិក្សានៅទេវវិទ្យាល័យ

៨ កក្កដា ៖ ប្រជុំលោកអភិបាលនិងតំណាងពេញសិទ្ធិ

១០ កក្កដា ៖ អភិបូជានៅអារាមកាម៉ែល

១១ កក្កដា ៖ ពិធីទទួលសញ្ញាបត្រសាលាអប់រំជំនឿសន្តយ៉ូស្ទីន

១០-១២កក្កដា ៖ ប្រជុំប្រធានយុវជន

១៣ កក្កដា ៖ បិទវគ្គសិក្សាសាលាមត្តេយ្យនៅចំការទៀង និងប្រជុំនៅភូមិសុខសាន្ត

១៧-១៩កក្កដា ៖ សិក្ខាសាលាអំពីព្រះគម្ពីរនៅភ្នំពេញថ្មី

១៩ កក្កដា ៖ ពិទទួលសញ្ញាបត្រ និងបិទឆ្នាំសិក្សានៅសាលាដុនបូស្កូភូមិច្រេះ

២០ កក្កដា ៖ ប្រជុំសាស្ត្រាចារ្យនៅវិទ្យាស្ថានសន្តប៉ូល

២៤-៣១កក្កដា ៖ ដំណើរទស្សនៈកិច្ចសិក្សាទៅទីក្រុងម៉ានីឡាប្រទេសភីលីពីន ជាមួយនិស្សិតសាលាសន្តយ៉ូស្ទីន

1Jul : Meeting with all general superior of Vietnamese congregations working in Phnom Penh Vicariat

2 Jul : Episcopal council at Phnom Penh Thmey.

6.30pm 40th night prayers for vocation at Kirivong

3 Jul : MEP meeting

4 Jul : Monthly meeting at Champa

5 Jul : Confirmation at Ponchentong

6 Jul : Visit of Australian Mission

7 Jul : Closing mass at Major Seminary

8 Jul : Bishops and vicars meeting

10 Jul : Carmel

11 Jul : Graduation ceremony at saint Justin school of Faith

10-12 Jul: Youth leaders meeting

13 Jul : Closing ceremony at Chomkarcheang Kindergarten.
Peace building party at Peace village

17-19 Jul: Bible seminar at Phnom Penh Thmey

19 Jul : Graduation ceremony at Phum Chres primary school

20 Jul : Meeting with Saint Paul teachers

24-31 Jul: exposure trip at Manilla Philippines with Saint Justin School of Faith



# រូបភាពប្រចាំខែ


អភិបូជាប្រចាំឆ្នាំរបស់បូជាចារ្យប្រចាំភូមិភាគភ្នំពេញ


លោកបូជាចារ្យ ដែលបានតែងតាំងជាបូជាចារ្យនៅក្នុងខែមិថុនា-កក្កដា


ប្រជុំក្រុមប្រឹក្សាលោកអភិបាលលើកទី១០០


សំណាក់ធម៌បូជាចារ្យទូទាំងប្រទេសនៅកំពង់សោម


លោកអភិបាល និងលោកបូជាចារ្យចូលរួមអភិបូជាលើកទីមួយ
របស់លោកបូជាចារ្យ សិលា សុខ ណា នៅព្រះសហគមន៍ផ្សារតូច


លោកអភិបាល និងលោកបូជាចារ្យជាតិកម្ពុជាទាំង៨រូប


ក្រុមគណកម្មការរៀបចំទិវាយុវជនកម្ពុជា-ឡាវ


លោកអភិបាលលាបប្រេងលើអាសនៈនៃព្រះវិហារថ្មីនៅអ្នកលឿង


APOSTOLIC VICARIATE PHNOM PENH
អ្នកទទួលខុសត្រូវៈ លោកអភិបាល អូលីវីយេ ឝ្មិតអឺស្លែរ
Chairman: Msgr: Olivier Schmitthaeusler
Tel: 023 64 00 841
Email: apostolicvicariate.phnompenh@gmail.com
#25, St.242, Boeung Prolit, 7Makara, Phnom Penh.
Website: www.catholicphnompenh.org
FP: www.facebook.com/catholicphnompenh


**វិទ្យុវ៉ារីតាសអាស៊ី**
**សម្លេងផ្សាយពីព្រះសហគមន៍កាតូលិក**
ផ្សាយជារៀងរាល់ថ្ងៃ
ភ្នំពេញ តាមរយៈរលកសម្លេង ៖FM104Mhz
កំពត តាមរយៈរលកសម្លេង ៖FM93.25Mhz
ក្រុងព្រះសីហនុ តាមរយៈរលកសម្លេង ៖FM92.5Mhz
វេលាម៉ោង ៖ ៥:០០-៦:០០ ល្ងាច

**កម្មវិធីវិទ្យុ " ខ្ញុំត្រូវការអ្នក "**
**តាមរយៈរលកសម្លេង**
FM 99.5Mhz
ផ្សាយជារៀងរាល់ថ្ងៃ
វេលាម៉ោង ៖ ១០:០០-១១:០០ ព្រឹក